CEN
CAMBODIA EXPRESS NEWS

រឿង

# "កញ្ញាកំសត់"

(ប្រលោមលោកក្នុងមនោសញ្ចេតនា)

**និពន្ធដោយ គឹម សែត**

**ផ្សាយចេញពី**

**បណ្ណាគារ អ៊ឹង-ហ៊ុន**

**លេខ ៥៨ តិរវិថីព្រះនរោត្តម**

**បាត់ដំបង**

**រក្សាសិទ្ធ**

**ព.ស.២៥០២** **គ.ស.១៩៥៩**

បោះពុម្ភឡើងវិញដោយបណ្ណាគារ "**អង្គរធំ**"

អាសយដ្ឋានៈ ១៤៩អ៊ីសូឡ, វិថីខេមរភូមិន្ទ, ភ្នំពេញ

ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១០ ២៥៨

ឆ្នាំ ២០០២

(បោះពុម្ភក្នុងខ្នាតៈ ២០ × ១៤ សង់ទីម៉ែត្រ)

រូបក្របៈ គូឡើងវិញដោយវិចិត្រករ **ខៀវ ចាន់ថារា**

ទូរស័ព្ទលេខៈ (៨៥៥) ១២ ៩៤៥ ៦៣២)

(គូរតាមរូបដើមទាំងស្រុង)

វាយអត្ថបទដោយកញ្ញា **លី សុន្ធរី**

ម៉ូតអក្សរ Limon S2 ទំហំ ២២

រចនាឱ្យចេញជាសៀវភៅដោយលោក **ហាក់ ទ៉ាន់ដារា**

កែអក្ខរាវិរុទ្ធដោយលោក **សំ ពិសិដ្ឋ**

(កែតាមសំណេរដើមទាំងស្រុង)

ឯកសារដើមបានមកពីគម្រោងស្រាវជ្រាវ

"វិវឌ្ឍន៍អក្សរសិល្ប៍ខ្មែរសតវត្សរ៍ទី២០"

## អារម្ភកថា

ស្នាកស្នាមប្រវត្តិសាស្ត្រជាច្រើន បានបង្ហាញឱ្យឃើញថាជនជាតិ ខ្មែរ ជាជនជាតិមួយមានខឿនអរិយធម៌ វប្បធម៌រុងរឿង។ ទោះបីជាមាន ការរុកទន្ទ្រានពីសត្រូវជិតខាង ឬមានចំបាំងរាំងជល់ផ្ទៃក្នុងក៏ដោយ ក៏ វិស័យសិល្បៈអក្សរសិល្ប៍របស់ខ្លួននៅតែបន្តការវិវត្តន៍ឥតឈប់ឈរ។ ប៉ុន្តែគួរឱ្យអនិច្ចាឆ្នាំ ១៩៧០ រដ្ឋប្រហារមួយ បានទម្លាក់ព្រះមហាក្សត្រ ព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** ដែលព្រះអង្គ តែងយកព្រះទ័យទុក ដាក់លើវិស័យអក្សរសាស្ត្រជាតិ រហូតប្រជាពលរដ្ឋបានថ្វាយព្រះនាមព្រះ អង្គជាព្រះបិតាអក្សរសាស្ត្រជាតិ។ សង្គ្រាមរបបប្រល័យពូជសាស្ត្រន៍បាន បំផ្លិចបំផ្លាញជាតិគ្រប់ វិស័យស្ទើរដល់កម្រិតសូន្យ ក្នុងនោះមានស្នាដៃ អក្សរសិល្ប៍ផងដែរ ។ ក្រោយពីមានការបង្រួបបង្រួមជាតិ ក្រោមព្រះរាជ កិច្ចដឹកនាំ របស់ព្រះមហាក្សត្រ ជនជាតិខ្មែរបានរួបរួមសាមគ្គីគ្នា ជាធ្លុង មួយស្តារនិងកសាងជាតិឡើងវិញ។ ដោយយល់ឃើញពីសារៈសំខាន់នៃ វិស័យអក្សរសិល្ប៍ ក្នុងការលើកស្ទួយវប្បធម៌របស់ខ្លួន បណ្ណាគារ "អង្គរធំ" យើងខ្ញុំបានសម្រេចលើកយកស្នាដៃប្រលោមលោកចាស់ៗរបស់អ្នកនិពន្ធ ដែលធ្លាប់មានឈ្មោះល្បីមកធ្វើការបោះពុម្ពឡើង វិញ ក្នុងគោលបំណង ថែរក្សានូវសម្បត្តិរួមរបស់ជាតិ ដើម្បីឱ្យកូន ខ្មែរជំនាន់ក្រោយៗបានចេះ ដឹងគ្រាន់ ជាគុណប្រយោជន៍រួមដល់សង្គមជាតិ។
ភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០២

## ១
## នៅមុខបណ្ណាគារសុវណ្ណភូមិ

-សួស្តី! អូនសៃហ្វា...

-ចាំ! សួស្តីបងណាត់! បងអញ្ជើញទៅណានុ៎ង?

-ខ្ញុំមកទិញប្រដាប់ការិយាល័យ។ ចុះសៃហ្វាទៅណាដែរ?

-ចាំ! ខ្ញុំមកទិញសៀវភៅមើលមួយពីរ ឮថាបណ្ណាគារនេះ បោះ ផ្សាយសៀវភៅថ្មីច្រើនណាស់។

-លោកពូ និងអ្នកមីង សុខសប្បាយជាទេ សៃហ្វា? ហើយ សៃហ្វាធ្វើការនៅឯណាសព្វថ្ងៃ?

-ចាំ! ប៉ាម៉ាក់ខ្ញុំបានសុខសប្បាយទាំងអស់គ្នាចំណែកខ្ញុំៗធ្វើការក្នុងហាង "ឡឺរ៉ូយ៉ាល់"។ ចុះបងណាត់បានសុំធ្វើការកន្លែងណាឬនៅ?

-ខ្ញុំមានកន្លែងធ្វើការហើយ។ ខ្ញុំសរសេរកាសែតតាំងពីខ្ញុំត្រឡប់ មកពីស្រុកបារាំងម្ល៉េះ!

-ចាំ! ខ្ញុំដឹងហើយ តែថាក្រៅអំពីរបរកាសែត បងមានសុំធ្វើការ ឯទីណាទេ ព្រោះខ្ញុំធ្លាប់ឮគេនិយាយថា "សរសេរកាសែតស៊ីមិនឆ្អែត ឡើយ"។

-រឿងក្រពះនោះ វាឃ្លានហើយ តែបើយើងគិតដល់ប្រយោជន៍ រួម យើងចេះតែស៊ូទ្រាំទៅបាន ណ៎ាសៃហ្វា!

-ហ៊ឹះ! ស៊ូទ្រាំ ស៊ូទ្រាំទៅបងណាត់ ស៊ូទ្រាំអត់បាយ! ស៊ូទ្រាំ ឱ្យគេជេរ! ស៊ូទ្រាំឱ្យគេគុំគួន...!

-អូហ៍ សៃហ្វា! អូនកុំនិយាយបញ្ឈឺចិត្តបងអញ្ចឹង! មនុស្ស ម្នាក់ៗបើរវល់តែខ្លាច រវល់តែរួញប្រមាត់ដូចគ្នានោះរកអ្នកចេញមុខធ្វើ កាសែតមិនបានទេ។ ...

នៅខាងមុខបណ្ណាគារ "សុវណ្ណភូម" អ្នកនិពន្ធប៊ុន-ណាត់ ហើយ និងនាងក្រមុំសៃហ្វា ឈរនិយាយគ្នាក្នុងបរិយាកាសរីករាយ និងស្មើភាព គ្នាទៅវិញទៅមក។

ប៊ុន-ណាត់ ជាសុភាពបុរស មានអាយុប្រមាណ ២៧ឆ្នាំ មាឌខ្ពស់ តែតូចស្តើង សក់កាត់ខ្លីហើយមានប្រជ្រុយមួយនៅក្រោមត្រចៀកឆ្វេង។ សំលៀកបំពាក់ស្អាតបាតតែមិនមែន "ធុនឌីត" នោះទេ។

នាងសៃហ្វា ក៏មានឬកពាគួរឱ្យស្រឡាញ់ដែរ។ នាងទើបតែពេញក្រមុំក្នុងឆ្នាំរកានេះ។ រូបនាងមិនសូវជាល្អឆើតឆាយណាស់ណាទេ តែនាងមានលំអពិសេសគឺៈ ទឹកមុខញញឹម មិនដែលដាច់។ សៃ ហ្វា គ្មានគ្រឿង អលង្ការដ៏ឆើតសម្រាប់លំអតួដូចកញ្ញាស៊ីវិឡៃដទៃឡើយ។ ក្រៅអំពីសំពត់ម៉ីអាខ្មៅ និងអាវស៊ីមិសម៉ូយ៉ែនពណ៌ខៀវខ្ចី គេឃើញតែកូននាឡិកាមួយនៅដៃឆ្វេងនាងប៉ុណ្ណោះ។ ចំណុចដែលធ្វើឱ្យប្រុសៗទាក់ចិត្តទៅលើ នាងយ៉ាងខ្លាំង គឺសម្លេងពិរោះ។ នាងមានសម្លេងស្រួយដូចសម្លេងសេកអញ្ចឹង។

អ្នកនិពន្ធប៊ុន-ណាត់ ក្រោយដែលបានរាប់រៀបប្រាប់រឿង សរសេរកាសែតដល់នាងសៃហ្វាហើយ ក៏បបួលនាងថាៈ

-តស់ យើងចូលទៅទិញអីវ៉ាន់។

-ចាំ!

ស្រីស្រស់ឆ្លើយថា ចាំ! ព្រមទាំងងក់ក្បាលបញ្ចេញទឹកមុខរីករាយ ដូចបុប្ផដែលទើបរីកថ្មីក្នុងពេលអារុណរះ។ នាងដើរចូលទៅក្នុងបណ្ណាគារ ដោយមានដំណើរទន់ល្វន់ល្អណាស់។ ស្រីស្រស់ដើររកមើល សៀវភៅក្រែងលោមានរឿងរ៉ាវណាជាទីគាប់ចិត្ត។ ចំណែកប៊ុន-ណាត់ វិញដើររកមើលប្រដាប់ការិយាល័យ។ គេទិញបានក្រដាសសរសេរមួយ ចំនួន ដបទឹកខ្មៅប៉ាកៀ១ ដងប៉ាកកា២ បន្ទាត់ ២ ហើយនិងក្រដាសផ្តិត២-៣សន្លឹក។ លុះគេឱ្យប្រាក់ទៅបណ្ណាគាររួចហើយ គេដើរសំដៅទៅកាន់នាងសៃហ្វា។ គេឃើញនាងក្រមុំកំពុង

ឈរនៅមុខទូដាក់សៀវភៅ ប្រលោមលោកខ្មែរ ដែលសុទ្ធសឹង ជាសៀវភៅតូចតាចស្ដែងពីរឿងកាម គុណ និងរឿង "ការបោយ"។ អត់ទ្រាំមិនបាន ប៊ុន-ណាត់ និយាយទៅ កាន់នាងក្រមុំថាៈ

-សែហ្វា កុំទិញសៀវភៅរបៀបនេះណ៎ាអូន!

-ចា៎! ខ្ញុំមិនទិញទេ ខ្ញុំគ្រាន់តែឈរមើលប៉ុណ្ណោះ វាព្រឺខ្នងណាស់ ទៅហើយ។

-ល្អណាស់អូន! កម្រមានស្ត្រីចេះញញើតសៀវភៅអានាចារដូច អូនណាស់។ មក! យើងទៅមើលទូសៀវភៅខាងណោះវិញ។

សែហ្វាដើរតាមក្រោយ ប៊ុន-ណាត់ តម្រង់ទៅទូសៀវភៅមួយដាក់ប្របនឹងជញ្ជាំងខាងលិច។ នៅពីមុខទូគេឃើញក្រដាសមួយសន្លឹកមានចារអក្សរថា Importation sans devise (នាំចូលដោយមិនបាច់មាន រូបិយប័ណ្ណ) នៅក្នុងទូនោះគេឃើញរឿងប្រលោម លោកបារាំង សុទ្ធសឹង ជាសៀវភៅពុករលួយទាំងអស់។ សែ ហ្វា យកសៀវភៅមួយមកមើល ឃើញមានចំណងជើងថាៈ (Allo! Amour) នៅទំព័រដើម នឹងបន្ទាត់ទីមួយនៃសៀវភៅនោះមានពាក្យមួយឃ្លាថាៈ (Des habillez-vous!) ស្រាតភ្លាមមក! ...។

សែហ្វា គ្រវីក្បាល។

-បងណាត់! បងណាត់មើលនែ!

ប៊ុន-ណាត់ ក្រឡេកមើលសៀវភៅនៅដៃសែហ្វា រួចសើច ញញឹម តែសើចហើយក្ដាប់មាត់បណ្ដើរផង។

-ណ្ហើយសែហ្វា វិលទៅផ្ទះវិញអូន!

-ឈប់សិន! ខ្ញុំរកទិញសៀវភៅត្រាតែបាន!

សែហ្វា ដើរតម្រង់ទៅទូមួយនៅជញ្ជាំងខាងជើងទៀត។ម្ដងនេះ នាងស្រីទិញបានតម្រាធ្វើម្ហូបមួយក្បាល សេចក្ដីផ្ដើមសិក្សាអំពីរឿងជាតិមួយក្បាល វប្បធម៌ជាតិមួយក្បាល ហើយនិងសៀវ ភៅប្រវត្តិអក្សរ សាស្ត្រខ្មែរមួយក្បាល។ នាងទិញបានសៀវភៅប្រលោមលោកមួយដែរ ឈ្មោះថា "សង្ឃឹមជានិច្ច"។ លុះទិញបានសៀវភៅហើយ នាងសួរទៅប៊ុន-ណាត់ :

-បងណាត់អញ្ជើញទៅណាទៀត?

-ខ្ញុំវិលទៅផ្ទះវិញ។

-ខ្ញុំក៏វិលទៅផ្ទះវិញដែរ។

នាងក្រមុំលើកដៃឆ្វេងឡើងមើលនាឡិកា រួចនិយាយថាៈ

-ម៉ោង ១០ហើយ!...

នាងសែហ្វានិងអ្នកនិពន្ធ ប៊ុន-ណាត់ បានបែកគ្នានៅម៉ោង ១០គត់។

# ២

# នៅក្នុងការិយាល័យកាសែត

រំលងពីរខែក្រោយមក... ប៊ុន-ណាត់ កំពុងអង្គុយធ្វើការ។ ការិយាល័យរបស់គេស្ថិតនៅផ្ទះលេខ២២ ផ្លូវព្រះបាទត្រសក់ផ្អែម។ ក្នុង ប៊ូយរ៉ូនេះមិនសូវមានតុតាំងកៅអីធុនថ្លៃទេ ។ បុគ្គលិកប្រាំពីរ នាក់អង្គុយ កៅអីឥតបង្អែក ហើយសរសេរនៅតុមួយវែងជាមួយគ្នា។ តុរបស់ប៊ុន-ណាត់ មានសភាពស្អាតបាតជាងគេបន្តិច ព្រោះអ្នកនិពន្ធនេះកាន់តំណែង ធំជាងគេ ដែលអ្នកផងហៅថាលោកបណ្ណាធិការ។ ភ្នាក់ងារកាសែតទាំងប៉ុន្មាន កោតខ្លាចនិងគោរពនាយប៊ុន-ណាត់ទាំងអស់ ដោយគេឃើញយុវជននេះ មានវិជ្ជាខ្ពង់ខ្ពស់ ហើយមានចិត្ត សប្បុរសល្អនិងទៀងត្រង់ផង។ ...

ប៊ុន-ណាត់ ជាកូនកសិករម្នាក់ នៅស្រុកកោះធំ។ មាតាបិតាក្រ ខ្សត់ណាស់។ ធ្វើស្រែមួយឆ្នាំមិនគ្រប់ស៊ីមួយឆ្នាំឡើយ ព្រោះ គ្រួសារនេះ មានគ្នាច្រើនហើយសុទ្ធតែជាមនុស្សមិនទាន់គ្រប់វ័យធ្វើការធ្ងន់ធ្ងរបាន។ ដោយហេតុថា ប៊ុន-ណាត់មានជីវភាពជុនដាបធ្លាប់ ទទួលការស្រេកឃ្លាន ក្នុងចំណោមអ្នកមាន ដូច្នេះបានជាគេមានគំនិតមិនពេញចិត្តនឹងវណ្ណៈនាយ ទុន តាំងពីកុមារមក។ លុះដល់ធំឡើង អាយុបាន២៣ឆ្នាំ គេទៅសិក្សាវិជ្ជានៅឯក្រុងប៉ារីសធានីប្រទេសបារាំង។ គេរៀនខាងសាលាពហុវិជ្ជា បានទទួលនូវជ័យជំនះយ៉ាងប្រពៃ តែ ក្រោយមកនិស្សិតកំសត់នេះដោយខ្វះការឧបត្ថម្ភក៏ត្រូវតែវិលមកកាន់មាតុប្រទេសវិញ។ មកដល់ភ្នំពេញវេលាណា គេបន្តដំណើរជីវិតរបស់ គេតាមគំនិតនិងមធ្យោបាយមួយដែល គេយល់ឃើញថាល្អ។ រាជរដ្ឋាភិបាលបានហៅ ប៊ុន-ណាត់ចូលធ្វើការរាជ ការនៅក្នុងមុខតំណែង ខ្ពង់ខ្ពស់ដែរ តែ ប៊ុន-ណាត់ប្រកែកដាច់អហង្ការមិន ព្រមធ្វើ។ ដោយមានជំនួយពីមិត្តភក្តិគេខ្លះ គេបោះផ្សាយកាសែតមួយច្បាប់ឈ្មោះថា "សច្ចះ" ចេញផ្សាយក្នុង ១អាទិត្យ ២ដង។

កំពុងតែអង្គុយសរសេរអត្ថបទ ស្រាប់តែឮសម្លេងនារីម្នាក់ ស្រែកហៅថា:

-បងណាត់! បងណាត់...

នាយប៊ុន-ណាត់ ងើបមុខឡើង ឃើញនាងសែហ្វាដើរចូលទៅដ៏ មានទឹកមុខស្រពោន សក់បះកន្ទ្រើងប្លែកពីធម្មតា។ នាយសួរ ភ្លាមថា:

-សែហ្វា ម៉េចក្រៀមក្រស់ម្លេះ? អូនឈឺឬ?

-ចាំ ខ្ញុំឈឺចិត្តណាំបង!

សែហ្វានិយាយដោយសម្លេងខ្សាវៗ ហើយមានទឹកភ្នែកហូរធ្លាក់ មកផង។

-ឈឺចិត្តនឹងអ្នកណា? រឿងអ្វីទៅ!

-ចាំ រឿងខ្ញុំនិងលោកថៅកែហាង "ឡឺរូយ៉ាល់"។

-មើល៍! អូនអង្គុយចុះសិនមក៏។

នាងក្រមុំដាក់គូថអង្គុយលើកៅអីមួយ នៅខាងមុខតុប៊ុន-ណាត់ ។ អ្នកនិពន្ធនេះសួរនាងទៀតថា :

-រឿងនោះដូចម្តេចខ្លះ អូនរ៉ាយរ៉ាប់ឱ្យអស់មើល៍។

-ចាំ រឿងខ្ញុំនោះយ៉ាងដូច្នោះ: កាលពីមួយខែកន្លងទៅហើយនេះ ថៅកែហាងឡឺរ៉ូយ៉ាល់ បានសុំសេចក្តីស្រឡាញ់អំពីខ្ញុំ។ គាត់ បានសន្យាថា បើខ្ញុំស្ម័គ្រចិត្តធ្វើប្រពន្ធចុងគាត់ៗនឹងសង់ផ្ទះថ្មឱ្យនៅទិញឡានឱ្យខ្ញុំជិះ ហើយគាត់បើកហាងកំណាត់មួយថ្មីឱ្យខ្ញុំរកស៊ី។ ខ្ញុំបាន ប្រកែកដាច់អហង្ការ ព្រោះខ្ញុំយល់ថាការដែលយកខ្លួន ទៅធ្វើប្រពន្ធចុងគេ មិនមែនជាការល្អប្រសើរឡើយ។ យើងយកប្តីគេ គឺយើងយក កង្វារទៅខ្វារបេះដូងប្រពន្ធដើមគេ នឹងកូនសំឡាញ់របស់គេពិតប្រាកដ។ យើងយកប្តីគេ គឺយើងទៅបំផ្លាញសុភមង្គលរបស់គ្រួសារគេ

ហើយ ចំពោះខ្លួនយើងទៀត គឺយើងនាំខ្លួនយើងទៅចូលភ្នក់ភ្លើង វិស័យដូចសត្វមមង់ ហើរទៅសម្លាប់ខ្លួនក្នុងភ្លើង ចង្កៀងយ៉ាង នោះឯង ។ ... ចាប់តាំងពីថ្ងៃដែលខ្ញុំមិនព្រមស្រឡាញ់គាត់ លោកថៅកែឡឺរ៉ូយ៉ាល់មានទឹកមុខមិនសប្បាយ ហើយចេះតែរករឿង ហេតុបង្ខូសខ្ញុំក្នុងកិច្ចការដែលខ្ញុំបានបំពេញដោយផ្ចិតផ្ចង់។ លុះមកដល់ ថ្ងៃទី ១៥ ខែមករា គឺម្សិលមិញនេះ គាត់បណ្ដេញខ្ញុំមិនឱ្យធ្វើការដោយសំអាងថាគាត់មិនសូវមានកិច្ចការច្រើន ណាមួយបុគ្គលិកច្រើនពេក គាត់ រកប្រៀវត្សរ៍ជូនមិនបាន ហើយជាពិសេសខ្ញុំនេះធ្វើការមិនសូវកើត!។

នាយប៊ុន-ណាត់ អង្គុយស្ដាប់បណ្ដើរងក់ក្បាលបណ្ដើរ លុះ សៃ ហ្វា និយាយចប់ គេឆ្លើយថា :

-គឺជាការធម្មតា សម្រាប់អ្នកនាយទុន។ នៅទីតំបន់ណានៅស្រុកភូមិណា នៅប្រទេសណាឱ្យតែមាននាយទុនក៏មានរឿងស្មោកគ្រោកមួយបែបនេះដូចគ្នាដែរ។

ឈប់ស្ងៀមមួយសន្ទុះ គេសួរសៃហ្វាទៀតថាៈ

-បើដូច្នេះ អូនគិតយ៉ាងម៉េច?

-ចាំ! ខ្ញុំគិតរកការងារថ្មីទៀត។

-រកការថ្មី! ខ្ញុំគ្រាន់តែឮថារកការថ្មីខ្ញុំងងឹតមុខភ្លាម ព្រោះថាបច្ចុប្បន្ននេះ ពិបាករកកន្លែងធ្វើការណាស់។ ស្រុកយើងជាស្រុកកសិកម្មអន់ថយ។ មនុស្សយកកំលាំងខ្លួនទៅទប់ទល់នឹងកំលាំងធម្មជាតិ។ ដូច្នេះមនុស្សត្រូវរស់ដោយលំបាក ហើយមនុស្សដែលគ្មានការធ្វើត្រូវតែបាន បង្កើនឡើង។ សៃហ្វាឃើញទេស្រុកយើងមានរោងចក្រប៉ុន្មាន? រោងចក្រធ្វើស៊ីម៉ង់ ធ្វើក្ដារបន្ទះ ធ្វើក្រដាស ធ្វើក្រណាត់ ធ្វើស្កររ បិទស្រា រំលាយ លោហធាតុ ធ្វើស្បែក ដំឡើងរថយន្ត។ សៃហ្វាដឹងទេ ស្រុកយើងមនុស្ស ដែលគ្មានការធ្វើ ដេកក្នុងវត្តអារាម ចាំរកកៅអីផ្សងតាមវាសនាមានចំនួនច្រើនណាស់។ តែណ្ហើយចុះសៃហ្វា! ខ្ញុំសូមជូនយោបល់ថា ក្នុងពេលដែល នាងអត់ការធ្វើនេះ នាងមកជួយសរសេរកាសែតខ្ញុំមក៏! ខ្ញុំលៃលកមិនឱ្យ នាងអត់បាយទេ ហើយប្រសិនបើនាងស្ម័គ្រចិត្តសរសេរកាសែតរហូតក៏ជា ការល្អដែរ ព្រោះស្រុកយើងមិនសូវមានស្រីៗចេញមុខសរសេរកាសែត ដូចស្រុកទេសគេជិតខាងនេះសោះ។

-ចាំ បើអញ្ចឹង ខ្ញុំសុំជួយសរសេរកាសែតបង ទំរាំពេលណារក ការបានធ្វើជាថ្មីទៀត។ ខ្ញុំមិនហ៊ានសរសេររហូតទេ ខ្លាចណាស់...

-បាន! ពេលណាអូនរកការបានធ្វើ ទៅធ្វើចុះ!

-ថ្ងៃណាបានឱ្យខ្ញុំមកសរសេរ?

-ថ្ងៃស្អែក។ តែបើចង់សរសេរឥឡូវនេះក៏បាន។

-ខ្ញុំមិនដឹងសរសេររឿងស្អីទេ?

-សរសេររឿង ដែលមិនសរសេរមិនបាននោះណ៎ា!

-រឿងអ្វីទៅ ដែលមិនសរសេរមិនបាន?

-រឿងវប្បធម៌ពុករលួយ រឿងឡឺរ៉ូយ៉ាល់ និងនាងសៃហ្វា... រឿង... រឿងជាច្រើនផ្សេងទៀតៈ រឿង រឿងសិទ្ធិមនុស្ស សិទ្ធិនារីនារី និងករណីកិច្ចនារីខ្មែរត្រូវមានអាកប្បកិរិយាបែបណា ។ល។

-បើដូច្នេះខ្ញុំសរសេររឿង "នារីគ្រប់លក្ខណ៍" វិញបានឬទេ?

-បាន ខ្ញុំត្រូវការរឿងហ្នឹងឯង។ ខ្ញុំទុកមួយទំព័រកាសែត សម្រាប់ ដាក់ "ទំព័រនារី"។

-ខ្ញុំមិនធ្លាប់សរសេរខ្លាចសរសេរមិនកើតណ៎ាបង!

-សរសេរទៅ! សឹមខ្ញុំជួយកែ។

សៃហ្វាសើចញញឹម។ នាយប៊ុន-ណាត់ បើកទូយកក្រដាស បួន ប្រាំសន្លឹកមកឱ្យ ហើយនិយាយថាៈ

-ខ្ញុំសង្ឃឹមថា កាសែតខ្ញុំនឹងបានលក់ដាច់ជាងលេខមុនៗ...

-ហ៊ឹះ! កុំនិយាយលេងបង!

-មែនណា៎អូន...

សៃហ្វាញញឹមអៀន។ នាងបានចូលរួមក្នុងគ្រួសារអ្នកនិពន្ធ តាំង ពីថ្ងៃនេះ (១៦មករា)។

៣

## នៅចន្លោះភ្នំដូនពេញ

សៃហ្វាជាខ្មែរមួយរូប មានជីវភាពដុនដាបណាស់។ ... នឹកដល់ប្រវត្តិរបស់នាងកាលណា អ្នកនិពន្ធខ្ញុំស្រក់ទឹកភ្នែកតក់ៗ មិនចង់សរសេរលាតត្រដាងនូវដំណើរការរស់នៅរបស់នាង ជូនលោក-អ្នកជ្រាបឡើយ។ តែណ្ហើយចុះ! ខ្ញុំសូមសង្ខេបរឿងយ៉ាងខ្លីដូចតទៅៈ "សៃហ្វាជានារីអភ័ព្វ។ នាងជួបប្រទះសេចក្ដីទុក្ខតាំងពីនៅក្នុងផ្ទៃមាតាម្ល៉េះ។ នាងគ្មានឪពុកទេ។ មាតានាងជាស្រីពេស្យាផ្កាមាស ដើររកស៊ីតាមសណ្ឋាគារបឹងស្នោ និង ជ្រោយអំពិល។ នាងចេញចាកផ្ទៃមាតាមកនៅថ្ងៃ ១៣ រោច ខែមិគ្គសិរ ព.ស២៤៦៤។ ចេញផុតផ្ទៃមាតាភ្លាមអ្នកស្រុកជិតខាងនាំគ្នាឱ្យឈ្មោះ នាងថា "កូនពេស្យា"។ លុះនាងអាយុបានមួយខួប អ្នកយ៉ុមជាមាតាក៏ អនិច្ចកម្មទៅ។ រឿងមរណភាពរបស់អ្នកយ៉ុមនេះទៀត ក៏គួរឱ្យអណោច អាធម្មណាស់។ គាត់ទៅស្លាប់នៅក្នុងមន្ទីរពេទ្យសំផឹងខាងលិចផ្សារថ្មី (ភ្នំពេញ)។ តាមប្រសាសន៍របស់លោក ផ.ស.ដែលជាអ្នកដឹងការច្បាស់ នោះ គឺអ្នកយ៉ុមនេះដើរលក់ឈាមរបស់ខ្លួន ដើម្បីយកប្រាក់កាសមកចិញ្ចឹមកូនង៉ែត។ ថ្ងៃមួយគាត់ឡើងទៅសណ្ឋាគារ "តឹងណាម" ស្វែងរក ជួបប្រុសៗ ស្រាប់តែភ្នាក់ងារប៉ូលិសតុលាការចាប់បញ្ជូនខ្លួនឱ្យទៅពេទ្យសំផឹង។ (ហៅគុកសំផឹងល្អជាង)។ ពីរបីថ្ងៃក្រោយមក អ្នកយ៉ុមមានជម្ងឺ គ្រុន ហើយក៏ផុតដង្ហើមក្នុងរវាងប្រាំបីថ្ងៃក្រោយមកទៀត។ ចំណែកខាង កូនង៉ែតរបស់គាត់ បានពូស៊ុមនិងមីងយ៉ែមយកទៅចិញ្ចឹម។ ពុស៊ុម និងមីង យ៉ែមគ្មានកូនទេ របររកស៊ីរបស់គាត់គឺ ធាក់ស៊ីក្លូ និងលក់ចេកអាំងតាមចិញ្ចើមថ្នល់។ ពីរនាក់ប្ដីប្រពន្ធនេះបាននាំយក "កូនពេស្យា" ទៅសុំចុះសំបុត្រកំណើតនៅសាលាសង្កាត់ លេខ៥ ដោយឆ្លើយថាកូនបង្កើតរបស់ខ្លួន ហើយបានដាក់ឈ្មោះថា នាង សៃហ្វា។ ពុស៊ុមស្រឡាញ់នាងសៃហ្វាណាស់ ។ តាំងពីបាននាងមកគាត់ខំរកស៊ីទ្វេមួយជាពីរ ពីព្រោះគាត់មិនឱ្យមីង យ៉ែមចេញទៅ ធ្វើការអ្វីទេ ទុកឱ្យនៅតែផ្ទះចាំបីបាច់រក្សាកូនស្រីមួយ យ៉ាង ប៉ុណ្ណោះ។ តែទុកជាប្ដីចែកនាទីយ៉ាងនេះក៏ដោយ មីងយ៉ែមនៅតែ ឆ្លៀតឱកាសដែលសៃហ្វាគេងលក់ ធ្វើនេះធ្វើនោះថែមទៀត។ គាត់បាន ទៅទទួលពីហាងថ្នាំអមតៈ ផ្ទះលេខ៣២ ផ្លូវសម្ដេចសង្ឃនាយកស្រីភ្នំពេញ នូវកញ្ចប់ថ្នាំទាំងឡាយយកមកបិទងផ្ទះ។ គាត់ស៊ីឈ្នួលបិទកញ្ចប់ថ្នាំក្នុង ១ថ្ងៃបានប្រាក់៥ ឬ៦រៀល ល្មមទិញស្លាម្លូ និងបារីឱ្យប្ដីសំឡាញ់គាត់ដែរ ។ មួយវិញទៀត គាត់មិនបាច់បង់ខាតប្រាក់ទិញឱសថមកព្យាបាលកូនស្រីឡើយ។ ហាងថ្នាំអមតៈ តែងផ្ដល់ឱ្យគាត់ នៅពេលដែលគាត់ត្រូវការ។ លុះសៃហ្វាចម្រើនវ័យវឌ្ឍនាបាន៧ឆ្នាំពូស៊ុមទៅសុំឱ្យចូលរៀននៅសាលាព្រះមទុមរាជា។ គាត់បញ្ជិះស៊ីក្លូជូនទៅជូនមករាល់ព្រឹកល្ងាច។ ថ្ងៃ៧ មិថុនា ឆ្នាំ ១៩៥៥ នាងសៃហ្វាបានប្រឡងជាប់សៃកទីហ្វិកា។ ឆ្នាំនេះនាង មានរូបរាងពេញក្រមុំហើយ។ នាងបានចុះឈ្មោះប្រឡងប្រជែងចូលអនុ វិទ្យាល័យព្រះនរោត្ដមដែរ តែប្រឡងធ្លាក់។ ហេតុដូច្នេះបានជានាងទៅសុំ ធ្វើការក្នុងហាង "ឡឺរ៉ូយ៉ាល់" វិញ ដើម្បីយកបៀវត្សរ៍មកចិញ្ចឹមមាតាបិតា ដែលកាន់តែមានកម្លាំងខ្សោយជាងមុន។ ឥឡូវនេះនាងក្រមុំមកជួយ សរសេរកាសែត "សច្ចៈ" ក្រោមការដឹកនាំនៃអ្នកនិពន្ធ ប៊ុន-ណាត់ ដែលមានជាប់សាច់សារលោហិតនឹងមីងយ៉ែមខ្លះដែរ។ កិច្ចនិពន្ធរបស់នាងបានទទួលសេចក្ដីសរសើរអំពីសំណាក់អ្នកអាន យ៉ាងខ្លាំង។ ក្រៅអំពី "នារីគ្រប់

លក្ខណ៍" នាងសរសេររឿងមួយទៀតឈ្មោះ "បញ្ហាគ្រួសារ"។ រឿងបញ្ហាគ្រួសារនេះមានខ្លឹមសារមិនចាញ់រឿង "ព្រះអាទិត្យថ្មីរះលើផែនដីចាស់" របស់ប៊ុន-ណាត់ ឡើយ។

តាំងពីនាងស្ម័គ្រចិត្តកាន់ស្លាបប៉ាកកាបំរើប្រយោជន៍រួម គេច្រើន ឃើញនាងដើរលេងជាមួយប៊ុន-ណាត់ ស៊ឹងតែរាល់ថ្ងៃ។ ថ្ងៃនេះគេឃើញឯមុខវាំងថ្ងៃនោះគេឃើញឯវត្តភ្នំ ថ្ងៃមួយនោះទៀត គេឃើញជិះទូកនៅ ក្រោមជ្រោយចង្វារ។ តែគេមិនដឹងច្បាស់ថាពីរនាក់នេះស្រឡាញ់គ្នាឬ ក៏មិនស្រឡាញ់ឡើយ។ ឱ! បើសិនជាគេថា ស្រឡាញ់គ្នាក៏យើងមិនបរិហា និន្ទាគេដែរ ផ្ទុយទៅវិញយើងជួយត្រេកអរទៀតផង។

ថ្ងៃមួយ ១៣មេសា វេលាម៉ោងពីររសៀល អ្នកនិពន្ធប៊ុន-ណាត់ និងនាងសៃហ្វា នាំគ្នាទៅអង្គុយក្រោមម្លប់ ឈើនាចង្កេះភ្នំដូនពេញ។ គេនិយាយគ្នាតិច១ច្រើន១ បណ្តើរគេះកន្ទួតជ្រក់បណ្តើរ។ ពេលនោះស្ត្រីកំសត់ម្នាក់ស្លៀកពាក់សំពត់អាវដាច់រយ៉ៃឱបកូនតូចមួយដ៏មានពោះ កំប៉ោះនៅដៃ ដើរចូលមករកគេ។ ដើរមកដល់ស្ត្រីកំសត់លុតជង្គង់ចុះ និយាយថា:

-ព្រះគុណម្ចាស់! ខ្ញុំសុំ ៥រ ទិញថ្នាំឱ្យកូន...។

សៃហ្វាឆ្លើយតបទៅវិញ:

-អត់លុយរាយទេ អ្នកមីង!

ប៊ុន-ណាត់ កែះសៃហ្វា កុំឱ្យនិយាយ ហើយគេសួរទៅមីងកំសត់ ថា:

-ម៉េចអ្នកមីងមិននាំកូនទៅព្យាបាលឯផ្ទះពេទ្យ។

ស្រីទុរគតសម្រក់ទឹកភ្នែកតក់១ តបមកវិញ:

-ខ្ញុំទៅផ្ទះដុកទ័រសាយ គាត់ទារថ្លៃថ្នាំច្រើនពេក ខ្ញុំអត់លុយក៏នាំ កូនមកវិញ... ណ៎ាព្រះគុណ!

-ដុកទ័រសាយ! (ប៊ុន-ណាត់និយាយខ្លាំង១)។ ដុកទ័រសាយមិន ដែលសង្គ្រោះអ្នកក្រម្តងទេ! ស៊ីឡើងគិតតែលុយ! លុយ! លុយ!... ហ៊ឺ! អ្នកជើងក្អែក!។

នាងក្រមុំសៃហ្វាយកដៃខ្ទប់មាត់ប៊ុន-ណាត់ ហើយសួរទៅអ្នក មីងកំសត់ម្តងវិញ:

-ម៉េចអ្នកមីង មិនទៅមន្ទីរពេទ្យរាជការ? នៅទីនោះមានគេ ជួយសង្គ្រោះអ្នកមីងគ្រប់វេលា។

-ខ្ញុំទៅដែរ... តែឥឡូវនេះខ្ញុំឈប់ទៅហើយ!

-ម៉េចឈប់?

នាងកំសត់មិនព្រមឆ្លើយ។ សៃហ្វាសួរទៀត:

-ម៉េចឈប់អ្នកមីង?

-អត់ទោស លោកស្រី! ខ្ញុំជំរាបលោកស្រីមិនបាន។

-រឿងអ្វីទៅ?

សៃហ្វាខំជជីកសួរ ចង់ដឹង។ ប៊ុន-ណាត់ស្រែកឃាត់:

-ស្ងៀមទៅសៃហ្វា គឺជារឿងធម្មតាទេ។

អ្នកនិពន្ធយើងអង្គុយមើលទឹកភ្នែកស្រីខ្មែរកំសត់មួយសន្ទុះ ទើប ហុចក្រដាសប្រាក់ ១០០រៀលទៅឱ្យ។

-អ្នកមីងយក ១០០រៀលនេះទៅទិញថ្នាំកែរោគឱ្យអាតូចចុះ។

នាងទុរគតទទួលយកលុយ ហើយលើកដៃសំពះឡើងលើបួងសួង ហៅទេវតាគ្រប់ទិសមកជួយថែរក្សាអ្នកសប្បុរសនេះ។

-ចាំខ្ញុំអរគុណហើយអ្នកមីង ទេវតាមិនអាចមកជួយខ្ញុំបានទេ។

សៃហ្វា និយាយទាំងទឹកមុខញញឹម។

ស្រីទុរគតសំពះលា ដើរចេញក្នុងចិត្តពោពេញទៅដោយសេចក្តី សង្ឃឹមថា កូនង៉ែតរបស់ខ្លួននឹងបានរស់រានមានជីវិតតទៅទៀត។

-ឃើញទេ! សៃហ្វា អត់លប់ទេ យកវិញ។

-គួរឱ្យអាណិតខ្លោចចិត្តណាស់បង!

អូនចេះអាណិតមនុស្សរបៀបនេះដែរ?

-ចាំ ខ្ញុំអាណិតអ្នកមីងអម្បាញ់មិញនេះណាស់ ហើយខ្ញុំចង់ទៅ សម្លាប់ដុកទ័រសាយភ្លាម ព្រោះលោកនេះគ្មានមនុស្សធម៌ក្នុងខ្លួនសោះ។

អូហ៏! អូនចង់ទៅសម្លាប់ដុកទ័រសាយ? គិតដូច្នេះខុសហើយ សៃហ្វា។ មនុស្សមិនត្រូវសម្លាប់មនុស្សទេ។ មនុស្សត្រូវជួយអប់រំមនុស្ស អាក្រក់ឱ្យបានជាមនុស្សល្អ។ ធ្វើដូច្នេះបានគេហៅថា កសាងសង្គម និង មនុស្សធម៌។

សៃហ្វាអង្គុយស្ងៀម។ ប៊ុន-ណាត់អធិប្បាយតទៅទៀតៈ

-មនុស្សម្នាក់មានសុខភាពមិនល្អ។ លើខ្លួនគាត់មានបូសបមកមរមាស់ និងដំបៅតូចធំជាច្រើន។ បើយើងចង់សាងខ្លួនមនុស្សនោះឱ្យបានល្អឡើងវិញ យើងត្រូវរកគ្រូពេទ្យយ៉ាងចំណានមកពិនិត្យមើល តើបូសកមរមាស់របស់គាត់នោះកើតមកអំពីអ្វី? មេរោគអ្វីបណ្តាលឱ្យមានជម្ងឺនោះ? កាលបើយើងរកឃើញរោគហើយ យើងយកថ្នាំមកចាក់ សម្លាប់មេរោគនោះឱ្យអស់ចេញបូសបមកមរមាស់នឹងបានសះជាស្បើយ ហើយរាងកាយរបស់មនុស្សនោះបានស្អាតល្អឡើងវិញមានកំលាំងពលំពេញបរិបូណ៌។ យ៉ាងណាមិញក្នុងការកសាងសង្គមមនុស្សក៏ដូច្នេះដែរ។ សង្គមដែលមានស្រីពេស្យាមានចោរខ្ជួញមានអ្នកធំរំលោភលើអ្នកតូច មានអ្នកក្រដើរសុំទានគេហៅថាសង្គមពុករលួយពោលគឺសង្គមមានដំបៅ ។ បើចង់ឱ្យសង្គមបានស្អាតឡើងវិញ គេត្រូវសំលាប់មេរោគចង្រៃ ដែលធ្វើឱ្យសង្គមកើតបូសបមកមរមាស់នោះ គេមិនត្រូវសម្លាប់មនុស្សអាក្រក់ ឱ្យអស់ពីក្នុងសង្គមទេ។

សៃហ្វាអង្គុយស្តាប់សេចក្តីពន្យល់របស់ ប៊ុន.ណាត់។ ស្តាប់រួច នាងគិត! ពិនិត្យវិនិច្ឆ័យយ៉ាងល្អិតល្អន់។ ទាំងពីរនាក់នេះអង្គុយក្រោមម្លប់ឈើ រហូតដល់ម៉ោង៥បានបបួលគ្នាទៅផ្ទះ។ ពេលដើរតាមផ្លូវគេនិយាយគ្នារងុម១ ហើយងក់ក្បាលម្តង១។ យើងមិនបានដឹងច្បាស់ថាគេនិយាយ រឿងអ្វីទេ។

៤

## នៅក្នុងផ្ទះលោកដុកទ័រសាយ

-អូនមិនប្រកែកឡើយ ហើយអូនត្រេកអរតតឧបមា បើសិនជា ពាក្យនេះបានឋិតនៅជានិច្ច។

-ពាក្យរបស់បង ជាពាក្យពិត។ ចូរអូនសង្ឃឹមហើយនិងធ្វើការ ឱ្យបងសង្ឃឹមផង។

-ចាំ ដូច្នេះយើងសង្ឃឹមទាំងអស់គ្នា។

នេះគឺជាសំដីក្រោយបំផុត របស់គិលានុបដ្ឋាយិកាជំនួយម្នាក់ ក្រោយដែលបានស្តាប់សំដីទឹកឃ្មុំរបស់ដុកទ័រសាយ។ លោករសាយស្រឡាញ់គិលានុបដ្ឋាយិកានេះណាស់។ តាំងពីនាងចូលមកធ្វើការក្នុងគ្រឹះ ស្ថានរបស់លោក១គ្មានប្រាថ្នាចង់បានអ្វីក្រៅពីរូបនាងឡើយ។ ពេលធ្វើការ ពេលដេក ពេលដើរ លោកមើលឃើញ ភ័ក្ត្រផូរផង់របស់នាងកញ្ញានេះ ទាំងអស់រហូតទៅដល់ដេកលក់ក៏យល់សប្តិឃើញ

នាងមកគេងជាមួយដែរ ។ ហេតុដូច្នេះគិលានុបដ្ឋាយិកាក្រមុំនេះ ក្រៅអំពីបៀវត្សរ៍បានទទួលប្រាក់អំណោយជាច្រើន ពីលោកដុកទ័រសាយទៀត។

ស្រីស្រស់ចេះធ្វើឫកពារញិកញ័ក់ និងញញឹមញញៀមដាក់លោក ធំនេះណាស់។ សំដីផ្អែម កាយវិការល្អ គំនិតបាន ឧស្សាហ៍ធ្វើការ គោរព ពេលវេលា គឺថាវត្ថុបំណងរបស់លោករសាយ ក្នុងការរើសប្រពន្ធ។ ឥឡូវ នេះ ស្ត្រីដែលមានលក្ខណៈដូចលោកប្រាថ្នាចង់បាននោះ បានចូលមកសុំធ្វើ ការក្រោមបង្គាប់លោកស្រាប់។ តើ! មិនឱ្យលោកងុបងុលដូចម្ដេចបាន?

ក្រោយដែលបានសម្លឹងមើលមុខស្រីស្រស់មួយសន្ទុះលោក ដុក ទ័រចូលទៅធ្វើការក្នុងបន្ទប់លោកវិញ។ នាងគិលានុបដ្ឋាយិកាក្រមុំនៅខាងក្រៅ ។ នៅវេលាម៉ោងប្រាំពីរ និងសាមសិបនាទី អ្នកជម្ងឺជាច្រើនទាំងប្រុសទាំងស្រីបានចូលមកពិនិត្យរោគ។ ក្នុងចំណោមនោះ មានអ្នកក្រីក្រមួយចំនួនដែរ។ នាងគិលានុបដ្ឋាយិកាកាលបើ ឃើញអ្នកកំសត់ចូលមកច្រើន ដូច្នេះក៏ម្នីម្នារត់ទៅសួរថាៈ

-អ្នកមីងឈឺដូចម្ដេច?

អូនតូចនេះឈឺប៉ុន្មានថ្ងៃហើយ?

ចុះលោកអ៊ុំនេះនៅដល់ណា? លោកយាយឈឺអ្វីដែរ? ។ល។

នាងសួរដូច្នេះ ព្រោះនាងអាណិតអាសូរអ្នកក្រ តែនាងមិនមែនជាអ្នកចេះពិនិត្យមើលជម្ងឺទេ។ នាងដឹងថាដុកទ័រសាយនិយមប្រាក់កាសជាងជីវិតអ្នកក្រីក្រ ម្ល៉ោះហើយនាងមិនទុកឱ្យអ្នកក្រត្រូវដុកទ័រសាយ បណ្ដេញចេញទេ នាងប្រញាប់ប្រញាល់បើកទូយកថ្នាំ អាស្ស៊ីព៊ីរីន, អាស្សព្រូ, គីនីន, ម៉ូម៉ាដ, ដាស៊ីណង់, គ្នានីដង់ ។ល។ មកចែកជូនដោយទឹក មុខញញឹមស្រស់។ នាងហ៊ានដូច្នេះព្រោះយល់ថាដុកទ័រស្រឡាញ់នាង ជោគជាំណាស់ មិនអាចជេរបន្ទោសនាងឬ បណ្ដេញនាងមិនឱ្យធ្វើការតទៅ ទៀតបានដោយងាយទេ។ នាងហុចគ្រាប់គីនីន៥គ្រាប់ ទៅយាយចាស់ម្នាក់។ នាងនិយាយដោយសំដីផ្អែមត្រជាក់ថាៈ

-សូមលោកយាយយកថ្នាំនេះទៅពិសារចុះ ថ្ងៃស្អែកយាយនឹង បាត់គ្រុនហើយ។

យាយចាស់ដ៏មានសក់ស្កូវសសំពោង ធ្មេញបាក់គ្មានសល់១ ក៏ លើកដៃសំពះនាងក្រមុំដែលមានអាយុមិនដល់ម្ភៃឆ្នាំផង។ ពេលនោះ លោកដុកទ័រសាយចេញមកទាន់។ នាងកញ្ញានិយាយទៅកាន់យាយចាស់ថាៈ

-សូមលោកយាយកុំសំពះខ្ញុំ។ អ្នកដែលមានគុណលើលោក យាយ គឺលោកដុកទ័រឯណោះទេ ខ្ញុំគ្រាន់តែជាអ្នកចែកថ្នាំប៉ុណ្ណោះ។

ឮដូច្នោះ យាយចាស់លុតជង្គង់ចុះ លើដៃពីរសំពះលោករសាយភ្លាម។ ដុកទ័រក៏សើចញញឹមពព្រាយដែរ។ ដោយឃើញមនុស្សចាស់សំពះខ្លួនដូច្នោះ លោករសាយត្រេកអរឥតឧបមា ហើយជាពិសេសការដែលគេ គោរពចំពោះមុខស្រីក្រមុំផង រឹតតែប្រសើរណាស់ទៀត។ អត់ទ្រាំឈរស្ងៀមមិនបាន លោករសាយមានប្រសាសន៍ទៅកាន់យាយចាស់ថាៈ

-លោកអ៊ុំ គ្រុនប៉ុន្មានថ្ងៃហើយ?

-ចាំ ៥ថ្ងៃហើយព្រះគុណម្ចាស់!

រួចដុកទ័របែរទៅកាន់គិលានុបដ្ឋាយិកាវិញៈ

-អូនឱ្យថ្នាំទៅលោកយាយបានប៉ុន្មានគ្រាប់?

-ចាំ បានតែ ៥គ្រាប់ទេបង!

-អញ្ចឹងទៅយក ៥គ្រាប់មកថែមឱ្យគាត់ទៀត!

ស្រីស្រស់អរណាស់ រត់ទៅបើកទូយកថ្នាំគីនីនមកភ្លាម។ នាង ហុចបំពង់ថ្នាំទៅដុកទ័រយកថ្នាំ ៥គ្រាប់ឱ្យទៅយាយចាស់ដោយផ្ទាល់ដៃលោក។ យាយចាស់ក៏លើកដៃសំពះម្ដងទៀត។

-ខ្ញុំមិនភ្លេចគុណព្រះគុណម្ចាស់ក្នុងមួយជីវិតនេះ និងក្នុងកាលដ៏ វែងឆ្ងាយតទៅទៀត។

-បាទ! អរគុណលោកអុំ។

យាយចាស់ដើរចេញទាំងទឹកមុខស្រស់បស់ថ្មីត្បិតតែគ្រូនគាត់ មិនញ៉ូវខ្លួនទទ្រើតដូចមុនទៀតឡើយ។ សំដីផ្អែមល្ហែមរបស់អ្នកធំ មិនងាយឯណាទៅរកបាន!។ ឥឡូវនេះ អ្នកក្រ ៤-១០នាក់ បានទទួលពាក្យ ផ្អែមត្រជាក់អំពីដុកទ័រសាយ ដូចយាយចាស់មួយនេះដែរ។ ការចំឡែកនេះ កើតឡើងដោយស្នាដៃនាងគិលានុបដ្ឋាយិកាទាំងអស់។ ដុកទ័រសាយនៅ វិយកម្លោះ ជាមនុស្សជោរចូល ចិត្តឱ្យគេលើកតំកើងខ្លួន ចូលចិត្តឱ្យចាស់ៗលុតក្រាប បានជានាងក្រមុំអូសទាញបានតាមចិត្ត។ បើលោកមិនព្រមតាមចំណង់នាង នាងធ្វើជាខឹងមិនព្រមហុចថ្ពាល់ឱ្យលោកថើបម្តងៗឡើយ។ ប្រុសៗចូលចិត្តថើបណាស់ គិតដូចម្តេចឱ្យតែបានថើបបង់ខាតតិចតួចមិនគិតដល់ទេ។ បើបានថើបព្រមទាំងបានទទួលកិត្តិយសថែមទៀត ឥតខ្លាច បង់ខាតសោះតែម្តង។ នេះគឺពេលចំពោះតែបុរសដែលស៊ីជោរ...តែបើ បុរសមិនស៊ីជោរវិញ យើងមិនអាចហ៊ានអាកាត់បានឡើយ ប៉ុន្តែក្នុងលោក នេះមនុស្សមិនស៊ីជោរ ហាក់ដូចជាពុំសូវមាន។ មួយវិញទៀត បើមានប្រហែលនឹងចៀសការភ្លាំងភ្លាត់ខ្លះមិនរួចដែរ។ ...

ពេលឈប់ធ្វើការ នាងកញ្ញាគិលានុបដ្ឋាយិកាជិះកង់វិលមកផ្ទះ ។ ធ្វើដំណើរតាមផ្លូវ នាងនឹកសង្ឃឹមម្នាក់ឯងថាគោលបំណងរបស់នាងនឹង បានសម្រេច បើនាងមិនបោះបង់ការព្យាយាមទេ។

## ៥
## នៅក្នុងភូមិអ្នកក្រ

ទ្រនិចនាឡិកាចង្អុលម៉ោងប្រាំពីរហើយ។ គឺថាពេលធ្វើការក្នុង ក្រសួងរាជការក៏ដូចជាក្នុងគ្រឹះស្ថានឯកជនដែរ។ ក្នុងផ្ទះលោកដុកទ័រ សាយ នាងគិលានុបដ្ឋាយិកាម្នាក់កំពុងបើកទូយកឱសថមកចែកជូនដល់ អ្នកជម្ងឺក្រខ្សត់ដូចថ្ងៃមុនៗ។

លោកដុកទ័រកាន់កាសែត "សច្ចៈ" មួយសន្លឹកនៅដៃដើរមករក នាងកញ្ញាដោយមានទឹកមុខញញឹម។ លោកហុចកាសែតទៅឱ្យនាងរួចមានប្រសាសន៍ ចំពោះមុខអ្នកក្រីក្រថាៈ

-ចូរអូនយកឱសថមកបើកជូនលោកពូ និងអ្នកមីងទាំងនេះផង។ គាត់ជាអ្នកទាល់ក្រយើងមិនបាច់គិតថ្លៃទេ។ យើងស៊ីចំណេញលើនាយទន់ និងអ្នកមានបៀវត្សរ៍ក៏ល្មមចិញ្ចឹមចិញ្ចឹមក្រពះដែរហើយ។

ឮសំដីលោកដុកទ័រពោលប៉ុណ្ណោះ បណ្តាអ្នកជម្ងឺក្រខ្សត់ទាំងឡាយលុតជង្គង់ចុះស្រែកថាៈ សាធុ! សាធុ! គ្រប់គ្នា។ នាងកញ្ញាសប្បាយចិត្តពេក រហូតដល់ភ្លេចការអៀនខ្មាសស្ទុះទៅឱបចង្កេះលោកដុកទ័រ យ៉ាងតឹងនិយាយថាៈ

-បងសំឡាញ់! វាចាដ៏ឈ្ងុយឈ្ងប់របស់បង ធ្វើឱ្យអូនសប្បាយ ហាក់ដូចជាបានត្រូវឆ្នោតហុកសិបម៉ឺន។

ដុកទ័រអង្អែលក្បាលគូសង្សារយ៉ាងថ្នាក់ថ្នម។

-គូជីវិតអើយ! គឺអ្នកក្រទាំងនេះហើយ ដែលធ្វើឱ្យយើងមាន កេរ្តិ៍ឈ្មោះល្បីល្បាញឡើង។ ចូរអូនមើលក្នុងទំព័រកាសែតនេះ។

មានប្រសាសន៍រួច ដុកទ័រដើរចូលទៅបន្ទប់លោកវិញ។ នាងក្រមុំ ចាត់ចែងចែកឱសថដល់អ្នកក្រ ។ លុះបំពេញកិច្ចនេះរួចហើយនាងទៅអង្គុយអានកាសែតនៅឯតុធ្វើការរបស់នាង។ នាងអានទាំងទឹកមុខញញឹម ហើយមិនបាច់មើលអក្សរទេ ។ បើសិនជានាងធ្មេចភ្នែកក៏នាងអានបានដែរ ថែមទាំងអានហូរដូចទឹកទៀតផង។

ក្នុងកាសែតនោះ មានអត្ថបទមួយសរសេរថាៈ

ដុកទ័រសាយ ជាអ្នកស្នេហាជាតិពិតប្រាកដ។

តាំងពីប្រទេសស្ថិតនៅក្រោមនឹមអាណានិគមបារាំងមកទល់នឹងប្រទេសបានឯករាជ្យពេញបរិបូណ៌ ដោយការដឹកនាំដ៏ភ្លឺស្វាងនៃសម្តេច ព្រះនរោត្តមសីហនុ គេទើបតែបានឃើញលោកដុកទ័រម្នាក់ទេ ដែលចេះគិតដល់តម្លៃជីវិតអ្នកក្រីក្រជាងប្រាក់ចំណេញកប់ក្តោងរបស់ខ្លួន។

លោកដុកទ័រនោះនាម ភួង-សាយ ជាបុត្រតែមួយរបស់ លោក ភួង-រត្ន និងលោកស្រីម៉ាលីឡា។

លោកភួង-សាយ នាំយកសញ្ញាប័ត្រពីប្រទេសបារាំងមកបំរើ ជាតិពិតប្រាកដ។ លោកបានបើកគ្រឹះស្ថានពិនិត្យរោគមួយនៅផ្ទះលេខ ១២២, ៥ផ្លូវឧកញ៉ាផ្លុងក្រុងភ្នំពេញ។ ប្លែកអំពីផ្ទះពេទ្យឯកជនទាំងឡាយ លោកដុកទ័រសាយបានទទួលមើលជម្ងឺអ្នកក្រខ្សត់ដោយឥតគិតថ្លៃឡើយ ។ តាំងពីព្រឹកទល់ល្ងាច គេឃើញអ្នកក្រទាំងប្រុសទាំងស្រី ចេញចូលទៅ ផ្ទះលោកឥតអាក់ខាន លើកលែងតែពេលបិទទ្វារ និងថ្ងៃអាទិត្យប៉ុណ្ណោះ ។

ចំពោះកាយវិការដ៏សប្បុរសរបស់លោកគ្រូពេទ្យនេះ ក្រុមសារពត៌មាន "សច្ចះ" សូមថ្លែងសេចក្តីសរសើរដ៏ស្មោះត្រង់ និងសូមប្រសិទ្ធិពរជូនលោកបានប្រកបនូវសេចក្តីសុខ និងមានកិត្តិស័ព្ទល្បី ល្បាញពេញ សាកលកម្ពុជា។

**ក្រុមសារពត៌មានសច្ចះ**

នាងគិលានុបដ្ឋាយិកាដាក់កាសែតនៅលើតុ រួចអង្គុយធ្វើការត ទៅទៀត។ ...

ពេលល្ងាចក្នុងថ្ងៃនោះ ដុកទ័រសាយមកឈរពីក្រោយខ្នង នាង ហើយដាក់ដៃទៅលើស្មានាងនិយាយថា:

-អូន !

-ចាំបង !

-យប់នេះ បងសូមអញ្ជើញអូនទៅមើលកុននឹងបងណា៎...នាងក្រមុំអង្គុយគិតមួយសន្ទុះ ទើបឆ្លើយតបះ

-ខ្ញុំចង់ទៅមើលកុនណាស់ តែក្នុងយប់នេះខ្ញុំមានធុរៈទៅមិនបាន សូមបងអត់ទោសឱ្យអូនផង...ដុកទ័រដកដង្ហើមធំះ

-អូនមានធុរៈអ្វី ? នាងកញ្ញាងើបមើលមុខដុកទ័រះ

-ចាំយប់នេះ អូនទៅសួរសុខទុក្ខដល់ស្ត្រីកំសត់មួយរូប ដែលទើប តែឆ្លងទន្លេរួច ហើយកំពុងមានជម្ងឺគ្រុនក្តៅផង។

-ម៉េចអូនមិនអញ្ជើញគាត់មកពិនិត្យរោគនៅផ្ទះយើង ?

-គាត់ឈឺធ្ងន់ណាស់ដើរមិនរួចទេ ហើយគ្មានប្រាក់កាសនឹងធ្វើដំណើរមកផង។ យប់នេះអូនចំណាយប្រាក់ផ្ទាល់ខ្លួនទៅទិញ ឱសថពីហាង ថ្នាំសង់ត្រាល់យកទៅជូនគាត់។

-បាច់ទៅទិញធ្វើអ្វី ថ្នាំរបស់បងមានគ្រប់គ្រាន់ដែរតើ !

-អូនមិនហ៊ានសុំ ខ្លាចបងអាក់អន់ចិត្ត។

-ទេ! កុំខ្លាចអញ្ចឹង ! បងមិនដែលប្រឆាំងនឹងគោលបំណងរបស់ អូនដល់ម្តងឡើយ។

នាងក្រមុំសើចញញឹម សំដែងនូវកាយវិការអៀនប្រៀន។

-អូនខ្លាចណាស់ !

-កុំខ្លាច ! អូនត្រូវការអ្វីប្រាប់បងមក បងជួយភ្លាម!

-ដុកទ័ររត់ទៅបើកទូយកថ្នាំគ្រុនមកឱ្យនាងគិលានុបដ្ឋា យិកា។ ស្រីស្រស់ទទួលហើយនិយាយថា:

-បើប្រសិនជាបងអញ្ជើញទៅជាមួយផង រឹតតែប្រសើរ ណាស់ទាន។

ដុកទ័រសើចញញឹមញញែម ព្រោះលោកពេញចិត្តនឹងសំដីនេះ ណាស់។ លោកមានប្រសាសន៍ថា :

-អូនអនុញ្ញាតឱ្យបងដើរជាមួយឬ ?

-ចាំ អូនពេញចិត្តឱ្យបងដើរជាមួយ។ អូនជាមនុស្សដែលចេះស្រឡាញ់គ្នា និងមិនខ្មាសអៀនទេ ក្នុងការដែលដើរជាមួយគ្នាចំពោះមុខ សាធារណៈជន។

-ដូច្នេះបងមិនទៅមើលកុនទេ ក្នុងយប់នេះ។ បងស៊ូតែពីដើរ តាមក្រោយអូន ! អូនទៅដល់ណាបងក៏ទៅដល់ទីនោះដែរ។

លោកដុកទ័រមានប្រសាសន៍បណ្ដើរ សរសៀចូលជិតនាងក្រមុំ បណ្ដើរ ហើយនៅទីបំផុតលោកឱបថើបថ្ពាល់នាងមួយខ្សឹត ពេញពោរទៅ ដោយសេចក្ដីសុខសាន្ត។

នាងស្រីនិយាយថា:

-កុំថើបខ្លាំងពេក នាំឱ្យឆាប់នឿយណាយទៅថ្ងៃក្រោយ។ ឥឡូវនេះដល់ពេលចេញទៅធ្វើការកុសលហើយ បើបងមិនទៅអូនទៅតែម្នាក់ ឯងក៏បានដែរ។

ដុកទ័រប្រញាប់ឆ្លើយតបភ្លាម:

-បងទៅដែរ... ចាំផង !

-ស្លៀកពាក់ភ្លាមមក៏ ! យប់ហើយតើ !

លោកសាយ ចូលទៅក្នុងបន្ទប់តុបតែងប្រាណយ៉ាងស្អាត។លោក ត្រេកអរនឹងការអញ្ជើញរបស់គូស្នេហាខ្លាំងណាស់។ ស្លៀកពាក់រួចស្រេច ហើយលោកនាំនាងឡើងរថយន្តពីមុតបរឆ្ពោះទៅកាន់ទីដែលនាងចង្អុលប្រាប់។

ពីមុតធុនថ្មី ពណ៌បៃតងខ្ចីហើយភ្លឺរលើបរលោង លូនតិច១ឆ្លងកាត់វិថីឧកញ៉ាផ្លុង មហាវិថីព្រះបាទមុនីវង្ស រុក្ខវិថីព្រះសីហនុ ផ្លូវស្ទឹងមាន ជ័យ... រួចទប់ហ្វ្រាំងឈប់ក្បែររោងអារឈើរបស់ថៅកែ ម៉េង-ស្រ៊ុន។

-ឈប់នេះហើយបង ! ផ្លូវចង្អៀតណាស់ចូលមិនរួចទេ។

នេះ គឺជាពាក្យបញ្ជារបស់នាងក្រមុំ ទៅកាន់លោកគ្រូ ពេទ្យ។

ឡានឈប់ភ្លាម គេទាំងពីរនាក់បើកទ្វារចុះបណ្ដើរគ្នាម្នាក់មុខម្នាក់ក្រោយ តាមផ្លូវបត់បែនមួយដូចស្នាមពោះលូនលើភូមិ អ្នកស្រុក។

ដើរបានប្រហែលម្ភៃជំហានទៅមុខ លោកគ្រូពេទ្យយកកូន កន្សែងខ្ទប់មាត់ ហើយខាកស្ដោះព្រូស១ និយាយថា:

-ទៅមិនបានទេអូន ផ្លូវនេះក្រខ្វក់ណាស់។ កុំទៅ ! វិលក្រោយវិញ បងក្អួតឥឡូវហើយ។

ដុកទ័រមិនហ៊ានដើរទៅមុខទៀត។ លោកស្រែកហៅគូសង្សារឱ្យវិលក្រោយ តែនាងកញ្ញាមិនព្រមវិល ពឹតតែពីដើរឱ្យលឿនជាងមុន។

-វិលក្រោយមក៏! បងក្អួតឥឡូវហើយ។វិលមក៏អូន ! វិលមក៏ ! ... ទៅមិនបានទេ...

ស្រីស្រស់ចេះតែឈានទៅមុខឥតងាកក្រោយ។ អត់ទ្រាំមិនបាន ដុកទ័រគ្រវីក្បាល ហើយរត់ទៅតាមដែរ។ លើផ្លូវនិងសង្ខាងផ្លូវគេឃើញ សុទ្ធតែអាចម៍ឆ្កែ អាចម៍ជ្រូក អាចម៍កូនក្មេង និង សម្រាមរលួយ ច្របូក ច្របល់គ្នានឹងទឹកនោម ធុំឆ្អេះខ្លាំងណាស់។ កណ្ដុរងាប់ហើមស្ដឹង ហើយនិង គម្រង់មាន់ទាធំស្អុយក្រៃណាស្អុយ។

ដុកទ័រដើរបណ្ដើរ ក្អួតបណ្ដើរ។

-បងខ្ពើមណាស់អូន ! យប់នេះញ៉ាំបាយលែងឆ្ងាញ់ហើយ។

នាងកញ្ញាតបវិញថា:

-មកអំពីដុកទ័រខ្ពើមកន្លែងហ្នឹងហើយ បានជាកន្លែងហ្នឹង មានសភាពក្រខ្វក់ម្លេះ។ គេថាកន្លែងណាដែលលោកគ្រូពេទ្យទៅដល់កន្លែងនោះនឹងមិនមានជម្ងឺទេ។ ដូច្នេះកន្លែងហ្នឹងនឹងបានស្អាតឡើងវិញ បើសិនណាលោកគ្រូពេទ្យអញ្ជើញមកជាញឹកញយ។ បងឃើញទេ ! កុមារពីរ បីនាក់ដើរខាងមុខយើងនោះមានពោះកំពឹងកំប៉ោង មុខមាត់ស្លេកស្លាំង ដោយជម្ងឺគ្រុន ។ បងឮទេ ! នៅសង្ខាងយើងសម្រែកថ្ងូររបស់មនុស្សឈឺគួរឱ្យខ្លាច។ ជម្ងឺទាំងនេះកើតមកអំពីភូមិស្រុកស្មោគគ្រោក ហើយភូមិស្រុកដែលមិនស្អាតនេះ ក៏មកអំពីដុកទ័រមិនព្រមចូលមកដឹកនាំឱ្យល្អដែរ។ ...

លោកសាយដើរដកដង្ហើមធំម្ដងៗ។ លោកខ្ពើមភូមិក្រខ្វក់នេះណាស់ តែលោកស៊ូដើរធ្មេចភ្នែកតាមក្រោយនារីដែលលោកស្រឡាញ់។ លោកមិនហ៊ាននិយាយឆ្លើយឆ្លងនឹងនាងទៀតទេ ។ ព្រោះសំដីរបស់នាង បាញ់ទៅចំក្រឡាអុករបស់លោកតែម្ដង។

រីឯនាងក្រមុំវិញ បោះជំហានទាំងញញឹមពព្រាយ។ ពេលណា នាងដើរទៅជួបកុមារា កុមារី ឬចាស់ព្រឹទ្ធាចារ្យមានជម្ងឺដំកាត់នាងហុច ថ្នាំទៅជូន ដោយមានវាចាផ្អែមល្ហែមថា:

-សូមអ្នកប្អូន អ្នកមីង ឬលោកពូយកថ្នាំនេះទៅពិសាចុះ! ថ្នាំនេះ ជាអំណោយដ៏បរិសុទ្ធរបស់លោកដុកទ័រ។

បណ្ដាអ្នកជម្ងឺទាំងតូចទាំងធំ លើកដៃសំពះលោកដុកទ័រ សាយ គ្រប់ៗគ្នា។ នេះគឺជាកិត្តិយសមួយដ៏ខ្ពង់ខ្ពស់ដែលលោកសាយបានទទួល ដោយស្នាដៃនាងក្រមុំ។

នៅតាមផ្លូវនោះ គេឃើញមាណពម្នាក់ស្ពាយម៉ាស៊ីនថតរូប ដើរ ចុះដើរឡើង ហើយលបសំឡឹងសំឡក់នាងគិលានុបដ្ឋាយិកា និងដុកទ័រ សាយម្ដងៗ។ លោកដុកទ័រមានប្រសាសន៍ទៅកាន់គូសង្សាថា:

-អ្នកថតរូបនោះមកពីណា ឬទៅណា ឃើញតែដើរចុះដើរ ឡើងគ្មានទីដៅសោះ។

នាងក្រមុំឆ្លើយតបយ៉ាងរួសរាន់។

-គឺជាអ្នកថតរូបគោចរ។ គេដើរថតយកទេសភាពទៅផ្ដិតលក់ ដូចដែលបងធ្លាប់ឃើញនៅគ្រប់បណ្ណាគារនោះឯង។

អ្នកថតរូបឮគេនិយាយដូច្នោះ ក៏ឈរស្ងៀមប្រុងត្រចៀកចាំ ស្ដាប់តទៅទៀត។

នាងក្រមុំនិយាយថា:

-ក្នុងលោកនេះ មនុស្សម្នាក់ៗមាននរបរទីទៃពីគ្នា ហើយដោយមានការប្ដូរផលរបរគ្នាទៅវិញទៅមក ទើបមនុស្សអាចរស់នៅបាន។ កសិករត្រូវពឹងពាក់ទៅលើជាងឈើ ជាងកំបោរ ជាងតម្បាញ ជាងដែក និងគ្រូពេទ្យ។ ឯគ្រូពេទ្យវិញក៏ត្រូវពឹងពាក់ទៅលើពួកគេទាំងនោះដែរ។ ហេតុនេះហើយបានជាអូនយល់ថា គួរតែបងកុំប្រមាទអ្នកធ្វើការដោយ កាយពល ហើយកុំស្អប់ខ្ពើមទីលំនៅរបស់គេ គួរតែឧស្សាហ៍ចូលមកឱ្យឱ វាទដើម្បីឱ្យគេបានស្គាល់តម្លៃអនាម័យខ្លះៗផង ។ ធ្វើដូច្នេះបងនឹងមាន កិត្តិយសខ្ពង់ខ្ពស់ថា ជាអ្នកស្រឡាញ់ជាតិ ហើយរូបអូនសោតទៀត ដែលនឹងបានជាភរិយារបស់បងទៅថ្ងៃមុខនោះក៏នឹងបានទទួលកេរ្តិ៍ឈ្មោះជាមួយនឹងបងដែរ។ ការដែលប្រជាជនយើងមានសុខភាពល្អ មិនមែនខូចខាតប្រយោជន៍យើងប៉ុន្មានទេ ព្រោះមនុស្សម្នាក់ៗមិនអាចគេចផុតពីជម្ងឺឡើយ។ បងនៅតែលក់ថ្នាំដាច់ដូចដើម។

អ្នកថតរូបស្ដាប់ឮដូច្នេះ ក៏សើចញញឹមពេញចិត្ត។ គេនិយាយរងំ តែម្នាក់ឯង តែល្មមឱ្យដុកទ័រសាយឮថា:

-ឱហ៎! សង្គមខ្មែរយើងមានអ្នកចេះស្រឡាញ់ជាតិដែរតើ ! ខ្ញុំនឹកស្មានថានៅស្រុកខ្មែរ គ្មានវរជនណាចេញមកធ្វើការបំរើរាស្ត្រតូចតាចទេ។ ឥឡូវខ្ញុំឃើញលោកប្រុស និងលោកស្រីមួយគូនេះចេះអាណិតអាសូររាស្ត្រ ទិញថ្នាំមកចែកជូនដោយសទ្ធាជ្រះថ្លា។ សូមឱ្យទេព្ដាជួយរក្សាលោក អ្នកសប្បុរសតរៀងទៅ។

និយាយរួច គេឈរកាន់ម៉ាស៊ីនថតសញ្ជប់សញ្ជឹង។ នាងកញ្ញា និង ដុកទ័រសាយ ចេះតែឈានជើងដើរទៅមុខទៀតរហូតទៅដល់ផ្ទះអ្នក មីងដែលទើបតែឆ្លងទន្លេរួច។

ផ្ទះនេះមានទិដ្ឋភាពទ្រុឌទ្រោមណាស់។ សរសរទាំងឡាយធ្វើ អំពីគល់ឫស្សី ដំបូលប្រក់ស្បូវបាំងជញ្ជាំងស្លឹក។ ពីមុខផ្ទះមានពាងបែក មាត់មួយដាក់ក្រោមដើមល្ហុង ក្នុងផ្ទះមានគ្រែចាស់មួយហើយនិងកៅអី មួយនៅសល់ជើងតែបី។ សំលៀកបំពាក់ របស់អ្នកមីងដែលព្យួរនៅជញ្ជាំង មិនគួរគប្បីនឹងមើលឡើយ ព្រោះមើលទៅហើយនាំឱ្យកើតមួម៉ៅនឹង ស្រទាប់មនុស្ស។ យើងអាចនិយាយបានថាសំពត់អាវទាំងនោះអ្នកមាន គេមិនយកទៅជូតអាចម៍កូនគេទេ តែអ្នកមីងយើងយកមកគ្របដណ្តប់ខ្លួនចេញដើរទៅផ្សារ ឬទៅធ្វើបុណ្យទានឯវត្តវ៉ា។

បែរមើលទៅចង្ក្រានបាយ ឃើញឆ្នាំងដីពីរបី ខ្លះបែកមាត់ ខ្លះធ្លុះ ក្តិត ខ្លះរេចរឹល គួរឱ្យនឹកសង្វេគដល់ការរស់នៅណាស់។ ឆ្នាំងបែក ! ចាន បែក ! ម្ហូបក៏មិនប្រសើរ តើបានរសជាតិពីណាមក។ តែអ្នកក្រនៅតែឆ្ងាញ់ ព្រោះក្រពះវាឃ្លានពេក។ តែឃ្លានហើយវាឆ្ងាញ់តែស្រឡាញ់ហើយវាល្អ! ... គឺភាសិតបូរាណរបស់ខ្មែរយើង។

ដុកទ័រចូលទៅដល់ឃើញអ្នកមីងយ៉ន់ដេកដណ្តប់ក្រមាររហែក ថ្ងូរហ៊ូស១។ អាតូចកូនគាត់ដេកនទៀលយំង៉ា១ក្បែរនោះដែរ។ នាងកញ្ញា គិលានុបដ្ឋាយិកាកាន់ជើងមីងយ៉ន់អង្រួន ហើយសួរថា:

-អ្នកមីង អ្នកមីងបានស្រួលខ្លួនជាងមុនទេ ?

អ្នកមីងបើកភ្នែកតិច១ ទាំងថ្ងូរបណ្តើរផង។

-អូយ! អូយ! ខ្ញុំឈឺចុកក្នុងខ្លួនណាស់។

គាត់ខំប្រវេប្រវាក្រោកឡើង។ លោកដុកទ័រមានប្រសាសន៍ថា:

-កុំក្រោកធ្វើអ្វី អ្នកមីង។ អ្នកមីងសម្រាន្តទៅខ្ញុំចាក់ថ្នាំជូន។

មីងយ៉ន់ដាក់ខ្លួនតិច១ទៅលើកន្ទេលវិញ។ នាងកញ្ញាគិលានុបដ្ឋា យិកា និយាយទៅកាន់គូជីវិតថា:

-សូមបងមេត្តាជួយសង្គ្រោះដល់អ្នកមីងផង។

និយាយរួច នាងក្រមុំទៅលើកអាតូចមកបីនៅដៃ។ លោកសាយក៏យកចិត្តទុកដាក់ពិនិត្យរោគ និងចាក់ថ្នាំឱ្យមីងយ៉ន់ តាមសេចក្តីអង្វររបស់ មាសស្នេហ៍។ លោកកំពុងតែដុសលាងម្ជុល មាណពថតរូបអម្បាញ់មិញដើរ ចូលទៅដល់ដែរ។ គេលើកម៉ាស៊ីនថតយកវិការដ្ឋានដ៏ខ្លោចចិត្តនិងប្រកបដោយមនុស្សធម៌នេះ។ ថតរួចគេដើរ ចេញទៅបាត់ទៅ។ លោកដុកទ័រនិងនាងក្រមុំមើលមុខគ្នាធ្វើភ្នែកឡឹនឡង់ ងឿងឆ្ងល់នឹងអ្នកថតរូបនោះណាស់។ លោកដុកទ័រ មានប្រសាសន៍ថា:

-អ្នកថតរូបនេះប្រាថ្នាអ្វី បានជាមកថតរូបយើងយ៉ាង

ដូច្នេះ?

នាងក្រមុំនិយាយថា:

-ខ្ញុំឆ្ងល់ណាស់ដែរ។

ទាំងពីរនាក់និយាយទៅកាន់គ្នារអ៊ុ១ ហើយខំធ្វើការព្យាបាលអ្នក ជម្ងឺដោយផ្ចិតផ្ចង់។ ពេលម៉ោង៩យប់បានគេនាំគ្នាសូមលាម្ចាស់ផ្ទះវិលមកកាន់លំនៅគេវិញ។ គេបរឡានតិច១តាមផ្លូវសំឡឹងមុខគ្នាទៅវិញទៅមក ហើយមកបែកគ្នានៅមុខសាលាសង្កាត់លេខ ៥។ នាងក្រមុំចូលទៅផ្ទះ របស់នាង។ លោកដុកទ័រ បរឡានតែឯកឯងចូលទៅលំនៅលោកដែរ។

# ៦

## នៅក្នុងភោជនីយដ្ឋាន "ថៃសាន"

"ថៃសាន" ជាភោជនីយដ្ឋានមួយ មានឈ្មោះល្បីល្បាញ ខាងធ្វើ ម្ហូបឆ្ងាញ់ក្នុងក្រុងភ្នំពេញ។ បណ្ដាលោកធំ និងអស់លោកថៅកែ លោកស្រី និងលោកជំទាវនិយមរាប់អាន "ថៃសាន" ណាស់។ ថ្ងៃនេះ"ថៃសាន"បានទទួលភ្ញៀវកុះករ។ ថ្នាក់ក្រោមក៏ដូចជាថ្នាក់លើគ្មានសល់កៅអីទំនេរដល់មួយសោះ។

នៅតុទី៥ ថ្នាក់ខាងក្រោម គេសង្កេតឃើញលោកដុកទ័រ សាយ លោកដុកទ័រហ្វ្រាំងស្វាជីម៉ារី លោកដុកទ័រង្វៀងយ៉ាំងមុីវ និងនាងក្រមុំគិលានុបដ្ឋាយិកាអង្គុយទទួលទានបបរយ៉ាងសប្បាយ។ ម្នាក់ៗមានទឹកមុខរីករាយពោពេញទៅដោយសម្ផស្ស។ លោក ដុកទ័រសាយមានប្រសាសន៍ ថា:

-នៅ ១៣ថ្ងៃទៀត ដល់បុណ្យរំឭកសិទ្ធិមនុស្សហើយ !

នាងកញ្ញាសួរថា :

-តើដល់ថ្ងៃនោះ បងនឹងធ្វើអ្វី ?

ដុកទ័រឆ្លើយឡើងភ្លាម :

-បងនឹងជួយជ្រោមជ្រែងដល់រាជរដ្ឋាភិបាល បើប្រសិនរដ្ឋាភិ បាលចាត់ចែងធ្វើការអ្វី។ តែបើដល់ថ្ងៃនោះ រាជការមិនធ្វើអ្វីទេ បងនឹង ទិញឱសថឱ្យបានច្រើនយកទៅចែកជូនដល់អ្នកក្រ។ បងធ្វើ ដូច្នេះអូន ពេញចិត្តទេ ?

-ចាំ អូនពេញចិត្តណាស់។

ដុកទ័របារាំង និងដុកទ័រយួន ស្ដាប់ពាក្យខ្មែរមិនបានក៏នាំគ្នាសួរ ថា:

-គេឺឱទើវ្វ ?

-អុងណយកែឃីដ ! ...

លោកសាយនិយាយភាសាបារាំងប្រាប់ទៅវិញយ៉ាងហូរហែ។ ដុកទ័របរទេសសើចចំអកហែះៗធ្វើឱ្យនាងក្រមុំមួម៉ៅចិត្តពន់ពេក។ ក្នុងពេលនោះ យុវជនម្នាក់ឱបកាសែតនៅដៃ ដើរចូលទៅលក់ ក្នុងភោជនីយដ្ឋាន។

-កាសែតអើ! កាសែត! ... កាសែតសាមគ្គី ! សច្ចៈវាចា ! មាតុ ភូមិប្រជាជន ! ពោលពាក្យធ្ងន់ប្រជាសេរី ?

ឃើញអ្នកលក់កាសែតដើរចូលទៅ នាងក្រមុំបក់ដៃហៅ :

-មកណែះ!

អ្នកលក់កាសែត ដើរឱនគ្រោនៗបែបខ្លបខ្លាច។ ទៅដល់លើក ដៃសំពះ ហើយហុចកាសែត "សច្ចៈ" មួយសន្លឹកទៅជូន។

-ថ្ងៃនេះកាសែត "សច្ចៈ" ល្អជាងគេ។

អ្នកលក់កាសែតពោលទាំងញ័រមាត់ ព្រោះពីថ្ងៃមុនមានជនឃោឃៅម្នាក់បានគម្រាមកំហែងមិនឱ្យលក់កាសែត "សច្ចៈ" ម្ដងទៅហើយ។

-ឱ្យកាសែត "ប្រជាជន" មួយសន្លឹកទៀតមក!

នាងក្រមុំបញ្ជាទៅអ្នកលក់។ យុវជនយកមួយសន្លឹកមក ជូនដូច ប្រាថ្នា។

-ថ្ងៃនេះប្រជាជនក៏ល្អដែរ...។ លោកស្រីទិញកាសែត "សាមគ្គី" មួយទៀតទៅ !។ ថ្ងៃនេះ "សាមគ្គី" យករឿង "បែក សាមគ្គី គឺស្លាប់" មក ធ្វើវិចារណកថា។

នាងកញ្ញានិយាយថា:

-ឱ្យមកមើល៏!

អ្នកលក់ក៏ហុចឱ្យមកទៀត។ ទទួលរួចហើយ នាងកញ្ញាឱ្យប្រាក់ ១០រ ទៅអ្នកលក់។ អ្នកនេះអាប់ ១រ មកនាងវិញភ្លាម។

នាងកញ្ញាមិនទទួលនិយាយថា :

-យកចុះ !

យុវជនថា "សូមអរគុណ" ហើយដើរទៅលក់កន្លែងផ្សេងវិញ។ នាងកញ្ញាគិលានុបដ្ឋាយិកាហុចកាសែត "សច្ចះ" ទៅឱ្យលោកដុកទ័រសាយ ។ លោកសាយពិនិត្យមើលអត្ថបទក្នុងកាសែតដោយផ្ចិតផ្ចង់។ អត្ថបទ មួយធ្វើឱ្យលោករំភើបចិត្តយ៉ាងខ្លាំង មានសេចក្តីថា:

"ដុកទ័រភួង-សាយជាអ្នកស្នេហាជាតិ-មាតុភូមិពិតប្រាកដ"

ក្រោមចំណងជើងនេះ មានរូបថតលោកដុកទ័រសាយកំពុងចាក់ ថ្នាំឱ្យមីងយ៉ន់ក្នុងខ្ទមជរាកាលពីថ្ងៃមុនមិញ។ តែគេមិនមានឃើញរូបនាងក្រមុំឡើយ។ ឯអត្ថបទនោះមានអត្ថរសដូចតទៅ:

កាលពីល្ងាចថ្ងៃអង្គារមុននេះ លោកវេជ្ជបណ្ឌិតភួង-សាយ បានស្ពាយវេជ្ជបករណ៏ផ្សេងៗ និងឱសថជាច្រើនមុខចូលទៅភូមិស្រុកអ្នកក្រ ដើម្បីចែកជូនដល់អ្នកជម្ងឺទាំងតូចទាំងធំ ទាំងប្រុស ទាំងស្រី ដោយសទ្ធាជ្រះថ្លា លោកបានពោលពាក្យផ្អែមពិរោះទៅកាន់អ្នកតូចតាចហើយបានជួយពិនិត្យជម្ងឺដោយយកចិត្តទុកដាក់ និងថ្នាក់ថ្នមបំផុត។ រូបភាពខាងលើ នេះគឺរូបលោកវេជ្ជបណ្ឌិតសាយកំពុងព្យាបាលជម្ងឺឱ្យមីង យ៉ន់ ក្នុងខ្ទមជរា នៅ "ស្ទឹងមានជ័យ"។

កាយវិការដ៏ប្រសើររបស់លោក សាយ បានធ្វើឱ្យយើងខ្ញុំបណ្តារាស្ត្រតូចតាចមានចិត្តរំភើបញាប់ញ័រគ្រប់ៗគ្នា។ យើងខ្ញុំសូមស្នើដោយគោរពដល់ព្រះរាជរដ្ឋាភិបាលថា: គួរតែព្រះរាជរដ្ឋាភិបាលជួយដឹងឮ និងជួយជ្រោមជ្រែងដល់កិច្ចប្រជា សង្គ្រោះរបស់ដុកទ័រខ្មែរមួយរូបនេះផង។

លោកសាយពេញចិត្តនឹងអត្ថបទនេះក្រៃលែង។ លោកបកប្រែ ជាភាសាបារាំងជូនលោក ប្រាំងស្វាដឺម៉ារី និងលោកង្វៀនយ៉ាំងម៉ីវស្តាប់។ លោកដុកទ័រទាំងពីរហាក់ដូចជាមិនសូវសប្បាយចិត្តទេ ព្រោះការដែលគេ សរសើរចំពោះតែដុកទ័រម្នាក់ ទុកដូចជាគេជេរដុកទ័រទាំងអស់ដទៃទៀត។

នាងគិលានុបដ្ឋាយិកាហុចកាសែត"ប្រជាជន"មកឱ្យលោកសាយ ។ ក្នុងកាសែតនេះមានអត្ថបទមួយសរសើរចំពោះដុកទ័រក្រោមចំណង ជើងថា:

> ប្រជាជនគ្រប់ជាន់ថ្នាក់បក្សពួក សូមសរសើរដល់ទឹកចិត្តនិងកាយវិការ នៃលោកដុកទ័រភួង-សាយ។

សាច់អត្ថបទក៏ប្រហាក់ប្រហែលគ្នានឹង "សច្ចះ" ពតិមានដែរ។ ក្នុងកាសែតសាមគ្គីមានអត្ថបទមួយទៀតអធិប្បាយយ៉ាងវែងក្បោះក្បាយ ក្រោមចំណងជើងធំៗថា:

លោកដុកទ័រសាយ និងរាស្ត្រតូចតាច។

អ្នកសរសេរអត្ថបទនេះ បានចុះហត្ថលេខាថា: កញ្ញា ភួង-មាលា ហៅសុវណ្ណចន្ទ ។...

គិតទៅក្នុងថ្ងៃនេះ កាសែតទាំងឡាយសុទ្ធសឹងផ្សាយពតិមាន អំពីកិច្ចការកុសលរបស់ដុកទ័រសាយទាំងអស់។

កិត្តិស័ព្ទរបស់ដុកទ័រកម្លោះនេះនឹងបានជ្រួតជ្រាបទូទៅក្នុងព្រះ រាជអាណាចក្រ ហើយប្រាកដជាបានពេញសាកលលោកផង ព្រោះក្រសួង ឃោសនាការ នៃស្ថានទូតនានានឹងបកប្រែដំណឹងនេះយកទៅផ្សាយឯស្រុក គេទៀតពុំខាន។

ទទួលទានបបររួច លោកដុកទ័រទាំងបីនាក់ ព្រមទាំងនាង គិលា នុបដ្ឋាយិកាផង សូមលាគ្នាទៅប្រកបកិច្ចការរៀងៗខ្លួន។

## ៧
## នៅក្នុងរបងកិត្តិយស

៥ខែរំលងក្រោយមក...ល្ងាចថ្ងៃសៅរ៍នេះ ផ្លូវព្រះអង្គអេងមាន ទិដ្ឋភាពប្លែកពីធម្មតា។ រថយន្តគ្រប់ចុននិងមនុស្សគ្រប់សញ្ជាតិបរចុះបរ ឡើង នឹងដើរចុះដើរឡើងខ្វាត់ខ្វែង ពីត្បូងទៅជើង ពីជើងទៅត្បូងយ៉ាងកកកុញ។ រថយន្តថ្មីៗចតត្រៀបត្រាខាងមុខគ្រឹះស្ថាន "កុញម៉េញ" មនុស្ស ម្នាទាំងប្រុសទាំងស្រីបណ្តើគ្នាចូលទៅគ្រឹះស្ថាននេះដោយទឹកមុខរីករាយ។

តាចាស់ម្នាក់ដុះស្បែកពោះធំស្ពុយ ដើរដំណើរឯកអោកៗនិយាយកាន់តាម្នាក់ទៀតមានមាឌស្គមតែខ្ពស់ថា:

-កាលពីមុនអាសាយ ជាមនុស្សខ្ជិលខិលគ្មានលេខដាក់។ វាជា មនុស្សទ្រុស្តមិត្ត កាចចង្រៃនឹងអ្នកក្រីក្រណាស់។ ហេតុអ្វីក៏វាប្រែគំនិតបានឆាប់រហ័សម្ល៉េះ?

តាដែលមានមាឌស្គមឆ្លើយឡើងថា:

-អ្វីៗក្នុងលោកនេះតែងតែប្រែប្រួលជាធម្មតា។ បើមានអ្នកជួយដឹកនាំផង នោះការប្រែប្រួលរឹតតែមានចលនាឆាប់រហ័ស ដែលគេមិន អាចនឹងស្មានត្រូវ។

តាចាស់ទាំងពីរបណ្តើរគ្នាឡើងទៅ "កុក-ម៉េញ"។ គាត់ទៅដល់ក្រោយគេបង្អស់។ គាត់ឃើញភ្ញៀវប្រហែលពីររយនាក់កំពុងលើកកែវស្រា សំប៉ាញចុះឡើងៗងក់ក្បាលទទ្រើតរកគ្នា។ គាត់ឃើញដុកទ័រសាយដើរចុះ ដើរឡើងពីស្តូកមួយទៅស្តូកមួយធ្វើបដិសណ្ឋារកិច្ចដល់ភ្ញៀវ។

លោកសាយបានផ្តើមធ្វើពិធីជប់លៀងនេះ ដើម្បីជាកិត្តិយសផ្ទាល់ខ្លួនរបស់លោក។ កាលពីប្រាំបីថ្ងៃកន្លងទៅនេះលោកបានទទួលមេដាយមាសពីព្រះមហាក្សត្របានទទួលសញ្ញាប័ត្រ និងសំបុត្រសរសើរពី គណៈរដ្ឋមន្ត្រីក្នុងការដែលលោកចេញទៅជួយសង្គ្រោះដល់អ្នកជម្ងឺក្រខ្សត់ ។

ក្នុងបណ្តាភ្ញៀវដែលអញ្ជើញមកទាំងប៉ុន្មាន គេឃើញនាងគិលានុបដ្ឋាយិកា ហើយនិងអស់លោកចាងហ្វាងកាសែតកម្ពុជាសាមគ្គី, ប្រជាជន, មាតុភូមិ, ប្រជាសេរី, ឈាមខ្មែរ, ប្រជាធិបតេយ្យ, មិត្តកម្មករ, សង្គមរាស្ត្រនិយម, ឯកភាព,មិត្តភាព,ទ្រុង ឡឹប, សុងដុង, មានទឹកមុខរីករាយជាងគេ។ ម្នាក់តំណាងកាសែត "សច្ចៈ" មិនសូវសប្បាយប៉ុន្មានទេ ព្រោះលោក ប៊ុន-ណាត់ដែលជាចាងហ្វាងនយោបាយ នៃអង្គការនេះ បានត្រូវជាប់គុកតាំងពី ៣ថ្ងៃ មកហើយ។ ចំណែកខាងពួកដុកទ័រវិញមិនសប្បាយចិត្តទាល់តែសោះ។ គេអញ្ជើញមកដោយខានមិនបានតែ ប៉ុណ្ណោះ។

ពិធីជប់លៀងនេះ ប្រកបទៅដោយភាពមនោរម្យយ៉ាងក្រៃលែង ។ ភ្លេងខ្មែរភ្លេងចិនបន្លឺឡើងរងំៗផ្ទុំគ្នា និងសម្លេងស្រួយរបស់នារីឯកខាង រាំច្រៀងនៅភ្នំពេញ ធ្វើឱ្យពួកតាៗក៏ដូចជាពួកកម្លោះៗមានចិត្តអណ្តែត អណ្តូងគ្រប់គ្នា។

ពិធីនេះបានបញ្ចប់នៅម៉ោង ១១យប់ គឺក្នុងពេលដែលសន្សើម ផ្តើមស្រក់មកស្រោចស្រប់ព្រះរាជធានី។

ពេលចេញដើរទៅផ្ទះ តាចាស់ដែលដុះស្បែកពោះ និយាយកាន់ តាស្គមទៀតថា:

-អាសាយជាប់ខ្លួនក្នុងរបងកិត្តិយសហើយ។ វាមិនអាចប្រ ព្រឹត្តអំពើអ្វីឱ្យផ្ទុយនឹងសកម្មភាពដែលវាធ្លាប់ធ្វើពីមុនទេ។ មែដាយមាស ! សញ្ញាប័ត្រ ! សំបុត្រសរសើរ ! គឺជារបងកិត្តិយសរារាំងវាមិនឱ្យងាក ចេញពីគន្លងដើម។ មិនតែប៉ុណ្ណោះកាសែតទាំងឡាយផ្សាយអត្ថបទ និងរូបថតរបស់វាសឹងតែរាល់អាទិត្យទៀត។ ទាំងនេះហើយ គឺជាច្រវាក់ចងជើង វាដោយវាមិនដឹងខ្លួន ! ...

តាស្គមមានប្រសាសន៍ថា:

-តាប៉ិងឯងកុំចេះតែថាឱ្យគេ។ ខ្ញុំឆ្ងល់ណាស់កាលបើឃើញនរណាមួយធ្វើការល្អ តាឯងចេះតែរិះគន់។ តាឯងចង់ឱ្យគេអារកស៊ីសាច់ហុតឈាមរាស្ត្រដូចតាឯងអញ្ចឹង ? មនុស្សម្នាក់ៗមានគំនិត ខុសគ្នាណាំតា ! ...។ តាឯងថា "រាស្ត្រស៊ីស្មៅ" ចំណែកគេឮថា "រាស្ត្រជាម្ចាស់ស្រុក"។ គេស្គាល់តម្លៃរាស្ត្រ បើតាឯងមិនស្គាល់ក៏ហីទៅ កុំថាជ្រៀមដាមឱ្យគេ...។

តាធាត់ខឹងនឹងតាស្គម ក៏ស្រែកគំហកថា:

-ស្ងៀមទៅអាសំគម ! បើឯងគ្រាន់បើ ម៉េចមិនទៅជួយភ្ជួរស្រែ រាស្ត្រទៅ?

-មិនទៅភ្ជួរ តែខ្ញុំមិនទៅបេះបោចដូចតាប៉ិងឯងទេ តាទាំងពីរមាន កំហឹងទល់កំហល់វៀងៗខ្លួន។ ដើម្បីកុំឱ្យកើតជាជម្លោះធំដុំ តាស្គមឡើង ជិះស៊ីក្លូទៅផ្ទះគាត់យ៉ាងរួសរាន់។ ចំណែកឯតាធាត់វិញ ឡើងជិះកាឌីយ៉ាក់ទៅវិមានគាត់ដែរ។

បណ្តាភ្ញៀវទាំងអស់ពុំបានដឹងរឿងកំប៉ិចកំប៉ុកនេះទេ។ គេនាំគ្នា ទៅផ្ទះទាំងស្រវឹងអួរព្រឆួរ។

ស្អែកឡើង នាងគិលានុបដ្ឋាយិកាមកធ្វើការ លោកសាយ ហៅ ចូលទៅក្នុងបន្ទប់របស់លោកនិយាយថា :

-គូជីវិតរបស់បង ! កាលពីមុនអូនប្រាប់បងថា : អូនសុខចិត្ត រៀបការនឹងបងនៅពេលណាដែលបងសុខចិត្តបំពេញបំណង ប្រាថ្នារបស់ អូន។ ឥឡូវនេះបងបានបំពេញរួចស្រេចបាច់អស់ហើយ បងសូមរៀបការ នឹងអូននៅថ្ងៃណាមួយឆាប់នេះ។

ចូរអូនមេត្តា កុំធ្វើឱ្យបងរង់ចាំយូរពេក។

ស្រីស្រស់សើចញញឹម ហើយអង្អែលខ្នងដៃដុកទ័រនិយាយថា:

-បងអើយ! អូនមិនចង់ឱ្យបងរង់ចាំយូរទេ តែធ្វើម្តេចបើកិច្ចការរបស់អូន មិនទាន់សម្រេចគ្រប់សព្វនៅឡើយ។ បងបានជ្រាបទេ?កិត្តិយសដ៏ខ្ពង់ខ្ពស់ដែលបងបានទទួល ក៏មកអំពីការជ្រោមជ្រែងយ៉ាងអស់ទំហឹងពី លោកប៊ុន-ណាត់ ចាងហ្វាងកាសែត "សច្ចៈ" ដែរ។ ឥឡូវលោក ប៊ុន-ណាត់ បានជាប់គុកធំរួចទៅហើយ។ អូនយល់ថាគួរតែបងជួយជ្រោមជ្រែង គាត់ផង ដើម្បីជាកិច្ចតបស្នងសងគុណ។ បងដឹងទេ ? អ្នកថតរូបដែលបង បានជួបនៅភូមិអ្នកក្រពីមុននោះ គឺលោកប៊ុន-ណាត់នេះឯង។ លោកប៊ុន-ណាត់បានយករូបបងមកចុះកាសែត ថែមទាំងបានសរសេរសរសើរបងសឹង តែគ្រប់ទំព័រកាសែតទៅហើយ។ ...

ដុកទ័រដកដង្ហើមធំ:

-ចុះអូនឱ្យបងជួយរបៀបណា ?

-អូនយល់ថា គួរតែបងយកឱសថ ប្រាក់កាស និងសម្ភារៈផ្សេងៗទៀតទៅជូនគាត់ផង។ សព្វថ្ងៃគាត់នៅក្នុងគុកអត់ឃ្លានណាស់ ព្រោះច្បាប់គុកតឹងរឹងពេកញាតិមិត្តមិនអាចយករបស់អ្វីទៅឱ្យបានឡើយ។ បងអាចយកទៅបាន ព្រោះបងស្គាល់គ្រូពេទ្យធ្វើការប្រចាំគុកស្រាប់។ បងផ្ញើលុយកាក់ ឱសថ និងសម្ភារៈផ្សេងៗ តាមលោកគ្រូពេទ្យ ព្រុក-ស្មុំ ហើយលោកនេះនឹងហៅលោកប៊ុនណាត់ទៅទទួលយកឯមន្ទីរពេទ្យគុកដោយស្ងាត់ៗ។

លោកដុកទ័រសើចញញឹម។

-បាន ! ខ្ញុំទទួលបំពេញភារកិច្ចនេះទៀត។

លោកប្រវារចាប់ដៃស្រីស្នេហ៍ ហើយនិយាយថា :

-អាអូនបងឆ្លាតណាស់ ! ចេះរកមធ្យោបាយសង្គ្រោះអ្នកទោស បានយ៉ាងងាយ។

ស្រីស្រស់ឆ្លើយថា:

-បើគ្មានបងក៏មិនងាយដែរ...

-មែន ! ... បើគ្មានបងក៏មិនងាយដែរ ។ អញ្ចឹងអូនដឹងគុណបង ទេ?

-ចាំ អូនមិនភ្លេចទេ?

# ៨

# នៅក្នុងពន្ធនាគារ

ម៉ោង៧ព្រឹក ។ អ្នកទោសទាំងឡាយ ទាំងប្រុសទាំងស្រីត្រូវបាន នាយភូឃុំ បើកទ្វារទ្រុងឱ្យចេញមកធ្វើការឯព្រលានខាងក្រៅ ។ ក្រុមនេះត្បាញកន្ទេល ក្រុមនោះធ្វើកៅអី ក្រុមនោះទៀត ធ្វើតុទូគ្មាននរណាមួយទំនេរដៃឡើយ ។ អ្នកខ្លះដងទឹកអ្នកខ្លះបោសសំរាម អ្នកខ្លះសែងអាចម៍ តាមសេចក្តីបង្គាប់របស់គុក ។ នាយប៊ុន- ណាត់ជាអ្នកទោសនយោបាយ ។ គេមិនត្រូវបានច្បាប់រដ្ឋបង្ខំឱ្យធ្វើការធ្ងន់ធ្ងរដូចពួកចោរស្រុកស្រែ និងពួកចោរកៅអីឡើយ ។ គេស្លៀកសារុងសូត្រពាក់អាវសឺមីសសអង្គុយអានសៀវភៅពង្សាតារនៅលើកៅអីផ្តៅមួយថ្មីចែស! ។

គេបើកសៀវភៅពង្សាតារមកអានភ្លាម ចំទៅលើរឿងមួយ យ៉ាងសំខាន់ ។ គឺរឿងយួនអាណ្ណាមដណ្តើមយកបានខេត្តខ្មែរនៅកម្ពុជា ក្រោម ។ អានដល់រឿងនេះ គេនឹកដល់អត្ថបទមួយចុះផ្សាយក្នុងកាសែត "ចឹងផុង" នៅព្រៃនគរកាលពីឆ្នាំ ១៩៥៣ ថា:

"ព្រះចៅង្វៀង ភឿក ង្វៀង (Nguyèn phuróc Nguyèn) ជាប្រមុខរដ្ឋអាណ្ណាម ។ ព្រះមហាក្សត្រអង្គនេះទ្រង់សោយរាជសម្បត្តិ ពី គ.ស ១៦១៣ ដល់ ១៦៣៥ ។ ទ្រង់មានព្រះរាជបុត្រីបួនព្រះ អង្គ ។ បុត្រី ច្បងនាម ង៉ុក-យ៉ាង (Ngoc Van) ។ ម្ចាស់ក្សត្រីអង្គនេះ ទ្រង់មានព្រះរូប នោមលោមពណ៌ល្អផ្ដាច់នារីក្រមុំទាំងឡាយនៅក្នុងជ្រោយសុវណ្ណភូមិ ។ បុរសណាបានឃើញព្រះនាងហើយ តែងអំណ្តែតអណ្តូងចិត្តគ្រប់គ្នា ។ ក្នុង គ.ស ១៦១៨ ព្រះចៅង្វៀង ភឿក ង្វៀង ទ្រង់លើកព្រះនាងនេះមកថ្វាយ ព្រះបាទ ជ័យជេដ្ឋាទី២ ជាប្រមុខរដ្ឋខ្មែរ កាលណោះព្រះបាទជ័យជេដ្ឋា ចំរើនព្រះជន្មបាន ៤៥ឆ្នាំ ។ព្រះអង្គសព្វព្រះរាជហឫទ័យនឹងម្ចាស់ក្សត្រី ង៉ុក-យ៉ាងណាស់ ។ លុះមកដល់ គ.ស ១៦២៥ ព្រះអង្គទ្រង់ព្រះសុវណ្ណ កោដិទៅ ក្នុងជន្មាយុ ៥២ឆ្នាំ (បានជួបមហេសី យួន៧ឆ្នាំគត់) ។ ម្ចាស់ ក្សត្រីង៉ុក-យ៉ាង ទ្រង់មានព្រះរាជបុត្រ ២ និងព្រះរាជបុត្រី ១ ។ ព្រះរាជបុត្រដែលបានសោយរាជ្យ គឺព្រះបាទបុទុមរាជា (១៦៦០ ដល់ ១៦៧២) ។" នឹកដល់រឿងយួនយកដីកូសាំងស៊ីន ប៊ុន-ណាត់មួម៉ៅក្តៅចិត្តណាស់ ។ គេដាក់សៀវភៅពង្សាតារចុះហើយយកសៀវភៅ "ព្រះមហាក្សត្រនៃ ប្រទេសកម្ពុជា" មកអានវិញ ។ ក្នុងសៀវភៅនោះគេឃើញ:

ការល្បងយកអាណាខេត្តខ្មែរ នៅប្រទេសវៀតណាមខាងត្បូង មកវិញ ។

១-ការល្បងយកដោយព្រះមហាក្សត្រ ។

២-ការល្បងយកដោយប្រជារាស្ត្រខ្មែរ នៅប្រទេសកូសាំងស៊ីន ។

៣-សេចក្តីទាមទារតវ៉ា ដែលព្រះបាទសម្តេចព្រះអង្គឌួង និង ព្រះបាទសម្តេចព្រះនរោត្តម ទ្រង់បានប្រារព្ធក្នុងពេលថ្មីៗនេះ..។

អានសៀវភៅ "ព្រះមហាក្សត្រនៃប្រទេសកម្ពុជា" ប៊ុន-ណាត់ មានសេចក្តីរំភើបចិត្តយ៉ាងខ្លាំងដោយបានឃើញការខិតខំតស៊ូរបស់ព្រះរាជា ដើម្បីទាមទារទឹកដីរបស់បុព្វបុរសមកជូនកូនចៅរបស់ព្រះអង្គវិញ ។

ប៊ុន-ណាត់ កំពុងតែនឹកគិតទៅដល់សកម្មភាពទាំងនោះស្រាប់តែ អ្នកទោសម្នាក់មកដល់លុតជង្គង់ចុះហើយលើកដៃសំពះ និយាយថាៈ

-ព្រះគុណម្ចាស់ ! លោកគ្រូពេទ្យឱ្យខ្ញុំមកអញ្ជើញព្រះគុណ ម្ចាស់ !...

ប៊ុន-ណាត់ ស្ទុះក្រោកចេញពីកៅអី ដើរតាមក្រោយអ្នកទោសតម្រង់ទៅមន្ទីរពេទ្យ។ (អ្នកទោសនេះជាកូនសិស្សសាលាព្រះជ័យជេដ្ឋា គុកឃើញវាមានសមត្ថភាពគ្រាន់បើព្រោះវារៀនដល់ដល់ថ្នាក់មធ្យមដ្ឋានទី២ដែរ ក៏បង្គាប់វាឱ្យទៅនៅធ្វើការក្នុងមន្ទីរពេទ្យរបស់គុក)។

ប៊ុន-ណាត់ ចូលទៅដល់ជួបនឹងលោកគ្រូពេទ្យ ព្រុក-ស៊ុំ លោក នេះហុចអីវ៉ាន់ដែលដុកទ័រសាយផ្ញើមកជូនដោយគោរព។

-ខ្ញុំអញ្ជើញលោកមក ដើម្បីទទួលយករបស់ទាំងនេះ (គ្រូពេទ្យ និយាយ)។

-នរណាផ្ញើមក? (ប៊ុន-ណាត់សួរ)

-លោកដុកទ័រសាយ ! លោកបានស្គាល់ដុកទ័រនោះទេ ?

-បាន ! ខ្ញុំស្គាល់ច្បាស់ !

លោកស៊ុំមានប្រសាសន៍ទៀតថាៈ

-សូមលោកយករបស់ទាំងនេះទៅទុកចុះ ហើយបើមានឈឺថ្កាត់ អ្វីសូមរួសរាន់មករកខ្ញុំ។

-បាទ ! ខ្ញុំសូមអរគុណ។

ប៊ុន-ណាត់យកអីវ៉ាន់ដើរចេញពីផ្ទះពេទ្យ។ គេខ្សឹបប្រាប់នាយ ភូ ឃុំម្នាក់ឱ្យបើកទ្វារឱ្យគេ យកអីវ៉ាន់ទៅទុកលើគ្រែដេក។ នាយភូឃុំក៏ធ្វើតាមឥតបង្អង់។ ដើម្បីជាការតបស្នងសងគុណ ប៊ុន-ណាត់ ឱ្យទៅនាយភូ ឃុំនូវបារីកូតាប ១កញ្ចប់ ផ្លែក្រូចពោធិសាត់២ និងប្រាក់២៥រៀល។

ពេលយប់នេះ ប៊ុន-ណាត់ ដេកមិនលក់ទេ។ ដោយបន្ទប់ដេកត្រូវ គេចាក់សោជាប់ ដើរចេញទៅណាមិនរួច អ្នកនិពន្ធយើងដេកដាក់ដៃគង ថ្ងាស គិតពីនេះបន្តិចពីនោះបន្តិច រួចនិយាយល្វើយៗម្នាក់ឯងថាៈ

-សៃហ្វា! សៃហ្វា ដ៏ជាទីស្រឡាញ់របស់បង !

បងដេកក្នុងគុក បងមិនភ្លេចទឹកមុខ និងវាចាផ្អែមពិរោះរបស់ អូនបានឡើយ។ ពេលថ្ងៃក៏ដូចជាពេលយប់ បងស្រមៃឃើញសោភណ្ឌភាពរបស់អូនជានិច្ច។ ជាតិនេះមាសពន្លករបស់បងបានទទួលទុក្ខវេទនាជាងស្ត្រីខ្មែរទាំងឡាយ។ តែកែវព្រលឹងបានបំពេញករណីយកិច្ចយ៉ាងគាប់ប្រសើរចំពោះជាតិ។ ក្រោមការអប់រំ និងការដឹកនាំរបស់បង អូនស្ម័គ្រចិត្តទៅធ្វើគិលានុបដ្ឋាយិកាបម្រើលោកសាយដើម្បីបំពត់ចរិយា និងគំនិតលោកនេះ ឱ្យបានទៅតាមគន្លងមនុស្សធម៌។ ឥឡូវអូនបានបំពេញករណីយកិច្ចចំពោះបងទៀត។ អីវ៉ាន់ដែលបងបានទទួលពីព្រឹកមិញនេះ គឺជាលទ្ធផលនៃការ ប៊ុនប្រសប់របស់អូន មិនមែនជាអំណោយដ៏សុទ្ធសាធពីដួងចិត្តលោកសាយទេ។

-សៃហ្វាអើយ!កិច្ចការដែលអូនធ្វើទាំងប៉ុន្មាន បានជូនផលប្រពៃ ដល់ប្រជាជនក្រីក្ររបស់យើង។ ប្រជាជនទាំងនោះក៏ដូចជារូបបងដែរមិន អាចបំភ្លេចគុណអូនបានឡើយ។...

ឥឡូវបងជាប់គុក បងឃើញមុខអូនបានតែមួយដងក្នុង១អាទិត្យប៉ុណ្ណោះទេ។ ពេលណាហ្ន៎! យើងនឹងបានទទួលសុភមង្គលជាមួយគ្នា។

ប៊ុន-ណាត់ និយាយល្វើយៗ ច្រំដែលៗតែម្នាក់ឯងក្នុងពេលដែល អ្នកទោសទាំងឡាយកំពុងដេកលក់ស្រមុកខ្ទឹតៗ។ គួរនឹកអាណិតដល់អ្នក និពន្ធកម្លោះនេះណាស់។ គ្នាជាប់គុកព្រោះតែរឿងជាតិ មិនមែនជាប់គុក ដោយទៅលួចទ្រព្យសម្បត្តិអ្នកដ៏ទៃ ឬបំបាត់ប្រវព្ធន៍ថវិការដ្ឋ សូម្បីតែ មួយសេនឡើង។

ឱ! អ្នកនិពន្ធ !!

៩

## នៅក្នុងភ្លើងរន្ធះចិត្ត

ធរណីមណ្ឌលវិលគ្រប់នាទី។ ថ្ងៃ និងយប់ដេញគ្នាហូរហែបន្តទៅ មុខឥតអាក់ខាន។ បើយើងរាប់តាំងពីថ្ងៃដែលអ្នកនិពន្ធប៊ុន-ណាត់ចូលទៅ កាន់គុកធំមកទល់នឹងថ្ងៃនេះបាន៦ខែ ១២ថ្ងៃហើយ។ ក្នុងកំឡុងកាលនេះ លោកដុកទ័រសាយមានសេចក្ដីសោកសៅយ៉ាងខ្លាំង ព្រោះនាងគិលានុបដ្ឋា យិកាក្រមុំមានទឹកមុខស្រពាប់ស្រពោន ជានិច្ច។ លោកសាយបង្ខំឱ្យនាង រៀបការ នាងចេះតែប្រកែកហើយនិយាយលួងលោមលោកវិញថា :

-សូមបងកុំប្រញាប់ប្រញាល់ពេក។ រង់ចាំលោកប៊ុន-ណាត់ចេញ ពីគុកសិនព្រោះគេជាអ្នកមានគុណលើយើង គួរតែបានមកចូលរួមក្នុងពិធី សុភមង្គលរបស់យើងដែរ។

លោកសាយទាល់គំនិតមិនដឹងជាគិតយ៉ាងណាទេ។ ភ្លើងតណ្ហាកាន់តែរាលដាលខ្លាំងឡើង១ៗសំដីរបស់នាងក្រមុំវិញ កាន់តែមានរសជាតិល្វីងបន្តិចម្តង១។ លោកសាយខ្សឹបប្រាប់មិត្តភក្តិលោកថា នាងកញ្ញាដែលលោកពេញចិត្តហាក់ដូចជាចង់ដោះដៃអំពីលោក។ ដុកទ័រហ្វ្រាំងស្វាដឹម៉ារី ដែលជាមនុស្សខូលខិលនឹងរឿងស្រី ឆ្លើយតបមកលោកសាយវិញថា :

-បើមិត្តមិនចង់ឱ្យនាងដោះដៃចោល មកត្រូវព្យាយាមយកខ្លួន ប្រាណនាងឱ្យបាន។ ស្រី១បើយើងមិនយកខ្លួនគេទេ គេថាយើងមិនចេះប្រដាប់យើងងាប់ គេបែកចិត្តពីយើងភ្លាម ! ...

លោកសាយស្តាប់សំដីលោកដុកទ័របារាំងរួច ក៏ងក់ក្បាលសំដែង នូវការយល់ស្រប។

ថ្ងៃមួយនាងក្រមុំកំពុងអង្គុយធ្វើការ លោកសាយចេញមកហៅ ឱ្យចូលទៅក្នុងបន្ទប់របស់លោក។ ស្រីស្រស់ចូលទៅតាមបន្ទាប់ដូចសព្វមួយដង។ នាងចូលទៅដល់ស្រាប់តែលោកដុកទ័របិទទ្វារគ្រឹប! ហើយចាប់ផ្ដួលនាងទៅលើតុសរសេរលោក ដែលមានទ្រង់ទ្រាយវែងដូចជាគ្រែដែរ។

នាងក្រមុំស្រែកសួរថា:

-លោកធ្វើស្អី ?

ដុកទ័រយកដៃទៅខ្ទប់មាត់នាង សង្កត់យ៉ាងខ្លាំង នាងខំបម្រះរួច ស្រែករំពងឡើង:

ជួយផង ! ជួយផង ! ប្រុសសាហាវធ្វើបាបខ្ញុំ... ជួយផង !

ស្លុតនឹងសម្រែករបស់នាង ដុកទ័រឈរស្រឡាំងកាំង។ នាងកញ្ញា ស្ទុះរួចពីកណ្ដាប់ដៃ ក៏ឈរទឹមចង្កេះជេរលោកដុកទ័រថា :

-លោកជាមនុស្សអាក្រក់ណាស់។ ខ្ញុំមិនត្រូវការលោក ទៀតទេ!

និយាយរួចស្រីស្រស់កន្ត្រាក់ទ្វារបើកចេញ ហក់ឡើងស៊ីក្លូតម្រង់ ទៅលំនៅមួយរំពេចនោះ។

នាយយករឿងនេះទៅជម្រាបតុលាការ ហើយនាងរង់ចាំរៀបអាពាហ៍ពិពាហ៍ជាមួយនឹង ប៊ុន-ណាត់ នៅពេលណាដែលអ្នកនិពន្ធនេះបាន រួចចេញពីការឃុំឃាំងមកវិញ។

~ចប់~